ក្រសួងអប់រំ យុវជន និងកីឡា

# គ្រូបង្រៀនស្រុកស្រែ

# ក្រុមខ្រៀនស្រុកស្រែ

# សេចក្តីផ្តើម

គ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ បានទទួលការអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡា ឱ្យបោះពុម្ពសៀវភៅ " **គ្រូបទ្រៀនស្រុកស្រែ** " ឡើងវិញ ដើម្បីរក្សាការពារកេរដំណែលវប្បធម៌ អក្សរសាស្ត្រជាតិ និងបំពេញសេចក្តីត្រូវការរបស់ប្រិយមិត្តអ្នកអាន និងសិស្សានុសិស្ស ។ ក្នុងការបោះពុម្ពផ្សាយឡើងវិញនេះ យើងខ្ញុំបានរក្សាអត្ថន័យអត្ថរស ខ្លឹមសារ និងឃ្លោងឃ្លា នៅដដែលទាំងស្រុង ។

យើងខ្ញុំរីករាយនិងរង់ចាំទទួលនូវការរិះគន់កែលម្អ ក្នុងន័យស្ថាបនាពីសំណាក់ប្រិយមិត្តអ្នកអាន និងសិស្សានុសិស្ស ដើម្បីធ្វើឱ្យការបោះពុម្ពផ្សាយលើកក្រោយៗកាន់តែសុក្រឹតថែមទៀត ។


បោះពុម្ពផ្សាយឡើងវិញតាមច្បាប់ដើម
ដោយគ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ
នៃក្រសួងអប់រំ យុវជន និងកីឡា

ព.ស ២៥៥៩ គ.ស ២០១៥

# អារម្ភកថា

រឿង "**គ្រូបង្រៀនស្រុកស្រែ**" បានបោះពុម្ពផ្សាយនៅខែ កុម្ភៈ ឆ្នាំ ១៩៥៧ បន្ទាប់ពីរឿង " គូលីកំនែន" របស់អ្នកនិពន្ធតែមួយ ។

រឿងនេះបានបំផុសការតស៊ូនយោបាយមានលក្ខណៈជ្រៅជ្រះជាងរឿង " គូលីកំនែន" ។ អ្នកនិពន្ធបានរៀបរាប់ពីចលនាឃោសនាផ្សព្វផ្សាយគំនិតប្រជាធិបតេយ្យសង្គមនិយម តាមខិតប័ណ្ណ បដា និងការជជែកគ្នានៃតួអង្គ ។

ចំណុចសំខាន់ ដែលអ្នកនិពន្ធបានលើកយកមកបកស្រាយ គឺការភ្ញាក់រលឹករបស់ប្រជាជននៅស្រុកស្រែពីការជិះជាន់របស់ពួកចក្រពត្តិនិយមអាមេរិច តាមល្បិចថ្មីក្រោយពីនឹមត្រួតត្រាអាណានិគមនិយមបារាំង ជប៉ុន បានរលំរលើងពីឥណ្ឌូចិន ។

យើងឃើញថា ក្នុងដំណើររឿង ចរន្តផ្សព្វផ្សាយឥទ្ធិពលល្អស្ដីពីលទ្ធិសង្គមនិយមត្រូវបានជនចម្រើន ដែលបានទទួលរស្មីនៃលទ្ធិនេះមុនគេយកមកឃោសនា ពន្យល់អប់រំ ដល់គ្រប់ស្រទាប់ប្រជាជន ។ ក្នុងចំណោមជន ទាំងនោះមាន កម្មករ កសិករ និងគ្រូបង្រៀន ដែលមានស្មារតីភ្ញាក់រលឹក បានចេញមុខប្រឆាំងនឹងអំពើអយុត្តិធម៌របស់ពួកអ្នកកាន់អំណាចនាសម័យនោះ ។ ទោះបីពួកអ្នកកាន់អំណាចប្រើមធ្យោបាយវាយបង្ក្រាប កាច់បំបាក់ ចាប់ដាក់គុក ខ្នោះឃ្នាង ច្រវាក់ សាហាវព្រៃផ្សៃ យ៉ាងណាក៏ដោយ ក៏ពួកជនដែលនៅសល់នោះ នៅតែបន្តការតស៊ូរំដោះជាតិជានិច្ច ។ ល្បិចគំរាមកំហែង សម្លុតស្មារតី មិនអាចយកជ័យជម្នះ លើទឹកចិត្តអំណត់អត់ធន់ សេចក្ដីអង់អាចឆន្ទៈការពារជាតិ ការពារសេរីភាព របស់ពួកគេបានឡើយ ។

នៅក្នុងសកម្មភាពដ៏ផុសផុលនេះ នារីក៏មានការភ្ញាក់រលឹកយ៉ាងខ្លាំងណាស់ដែរ ។ សកម្មភាពរបស់នារី ត្រូវបានអ្នកនិពន្ធលើកយកមកលាតត្រដាង បញ្ជាក់ឱ្យឃើញកាន់តែច្បាស់នូវការយល់ដឹងរបស់នារី លើបញ្ហាស្រុកទេស និងវិភាគទានដ៏សំខាន់របស់នារី ក្នុងចលនារំដោះជាតិ ។ ប្ដីត្រូវគេរកចាប់ នារីជាប្រពន្ធបន្តឧត្ដមគតិប្រជាធិប -

តេយ្យរបស់ប្ដី ។ នារីដទៃទៀតក្នុងភូមិចូលរួមដោះស្រាយរាល់ការលំបាកនានាដើម្បីឱ្យបំណងរបស់ប្រជាជន បានទៅដល់គោលដៅ ។ នារីមានការភ្ញាក់រលឹកខំរំដោះខ្លួនពីគ្រោះអវិជ្ជា បានតាមដានព្រឹត្តិការណ៍ប្រទេសជាតិយ៉ាងសកម្មថែមទាំងជួយលើកទឹកចិត្ត ប្ដី និងមិត្តភ័ក្ដិឱ្យមានដំណើរការល្អក្នុងការផ្សព្វផ្សាយគំនិតអធន ហើយនិងជួយរកវិធីទប់ទល់នឹងល្បិចបង្ក្រាប អ្នកតស៊ូពីសំណាក់ពួកអ្នកកាន់អំណាចពេលនោះផងទៀត ។

ក្នុងរឿងនេះ សកម្មភាពដែលលេចធ្លោជាងគេ គឺសកម្មភាពរបស់គ្រូបង្រៀន និងជនភ្ញាក់រលឹកចង់បានសេរីភាពប្រជាធិបតេយ្យ ។ អ្នកទាំងអស់នេះ ឈរលើឧត្តមគតិមួយដាច់ខាត គឺស្នេហា សន្តិភាព ស្នេហាមនុស្សជាតិ ស្នេហាសេរីភាព ។ ទិសដៅធំបំផុត គឺពួកគេធ្វើយ៉ាងណាវាយបណ្ដេញពួក ចក្រពត្តិឱ្យបានចេញផុតពីមាតុភូមិជាទីស្រឡាញ់ ហើយកសាងសង្គមមួយល្អបរិសុទ្ធ ។

ថ្វីបើរឿងគ្រូបង្រៀនស្រុកស្រែមានអត្ថន័យជ្រៅជ្រះជាងរឿងគូលីកំនែនក៏ដោយក៏រឿងនេះ ឋិតនៅក្នុងប្រភេទរឿងតថនិយមជឿនលឿន ។ ព្រោះថា រឿងនេះបានត្រឹមតែបំផុសចលនាតស៊ូនយោបាយឈានឡើងបដិវត្តន៍ ប្រជាជាតិ មិនទាន់ដល់កម្រិតតថនិយមសង្គមនិយមនៅឡើយ ។ នេះជាកត្តាសត្យានុម័តតាមតំណរយៈកាលរីកចម្រើននៃប្រវត្តិសាស្ត្រ ។

គណៈកម្មការ សុំកែសម្រួលអក្ខរាវិរុទ្ធតាមសំណេរបច្ចុប្បន្ន ឯឃ្លា ល្បះ រក្សាទុកដដែល ។

គណៈកម្មការយើងខ្ញុំ សូមផ្ញើទំនុកចិត្ត និងសេចក្ដីរាប់អានដ៏កក់ក្ដៅលើប្រិយមិត្តជាទីស្នេហា ក្នុងការផ្ដល់យោបល់រិះគន់ស្ថាបនាចំពោះកថាមុខនេះ ដើម្បីការរីកចម្រើននៃអក្សរសាស្ត្រជាតិយើង ។

ភ្នំពេញ , ថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ ១៩៨៣

គណៈកម្មការអក្សរសិល្ប៍ និងភាសា

# អារម្ភកថា

សៀវភៅ " **គ្រួចទ្រៀនស្រុកស្រែ** " ជាប្រលោមលោកលើកទី៣ ដែលយើងបានបោះពុម្ពផ្សាយបន្ទាប់ពី " ស៊ីមអ្នកបរឡាន " និង " គូលីកំនែន " ។

យើងបានរៀបរៀង " **គ្រួចទ្រៀនស្រុកស្រែ** " ដោយបានសម្រាំងយករឿងជាក់ស្តែងខ្លះ នៅស្រុកស្រែចំការ ។

ដូចសៀវភៅយើងមុនៗ យើងមិនបានធ្វើអត្ថាធិប្បាយខ្លួនយើងទេ យើងសូមគោរពអញ្ជើញបងប្អូនមើលពិចារណាកំសាន្ត ... ។

កុម្ភៈ ១៩៥៧

**អ៊ឹម - ថុក**

អតីតចាងហ្វាងកាសែត " វត្តភ្នំ "

# បញ្ជីអត្ថបទ

ទំព័រ

១. រកមិនជួប . . . . . . . . . . . . . . . . . . . . . ១
២. ខ្សឹកខ្សួល . . . . . . . . . . . . . . . . . . . . . ៤
៣. ជួយគ្នាទាន់គ្រាក្រ . . . . . . . . . . . . . . . . . ៧
៤. កាត់វាលស្រែពេលយប់ . . . . . . . . . . . . . . . ១០
៥. មធ្យោបាយផ្សេងៗ . . . . . . . . . . . . . . . . ១៥
៦. ស្រីៗ . . . . . . . . . . . . . . . . . . . . . . ១៧
៧. លោកប្អូនរបស់ពូព្រឿង . . . . . . . . . . . . . . ២០
៨. គុកខ្មែរ . . . . . . . . . . . . . . . . . . . . . ២៤
៩. បរិយាកាសគុក. . . . . . . . . . . . . . . . . . . ២៨
១០. យប់ក្នុងគុក . . . . . . . . . . . . . . . . . . . ២៩
១១. ពេលចូលកង . . . . . . . . . . . . . . . . . . . ៣១
១២. ហួសដូស . . . . . . . . . . . . . . . . . . . . ៣៤
១៣. វ៉ាកងខែចេត្រ. . . . . . . . . . . . . . . . . . . ៣៧

# ១. រកមិនជួប

... ថ្ងៃរសៀលម៉ោង៤ ។ ម៉ាស៊ីនស្រូវតូចមួយ នៅខាងកើតផ្លូវទៅភូមិគរ កំពុងរត់ញាប់រន្ថាន់ ។ នៅខាងលិចផ្លូវចំមុខម៉ាស៊ីននេះ រំលងផ្ទះមួយខ្នងធំ មានផ្ទះតៀមមួយ ។ ផ្ទះនេះមានបណ្ដោយប្រវែង ១០ម០០ ទទឹង ៥ម០០ បែងចែកជាពីរល្វែង ។ នៅខាងក្រោមល្វែងខាងជើង មានផ្ទះបាយមួយ ហើយជាប់ផ្ទះបាយនេះមានទ្រុងជ្រូក ។ ផ្ទះតូចនេះ ជាលំនៅរបស់អ្នកស្រែពីរគ្រួ : ពូព្រឿង និងបងហម ។

ពូព្រឿងចំណាស់ជាប់ ៥០ឆ្នាំ ។ គាត់នៅល្វែងខាងត្បូង ភ្នែកគាត់ឈឺមើលអ្វីមិនបានឆ្ងាយ ។ រោគស្ពឹកបានរោមរឹតគាត់ ឃាត់គាត់មិនឱ្យដើររកស៊ីក្រៅផ្ទះ ។ គាត់នៅចាំផ្ទះមើលថែទាំកូនតូចៗបួននាក់ ។ តែគាត់មិនមែន ជាអ្នកទម្រន់ដេកស្ងៀមឡើយ ។ នៅផ្ទះគាត់ឆ្លៀតត្រដរដាំអំពៅ ដាំស្លឹកគ្រៃ ដំឡូងឈើ ចិញ្ចឹមកូនជ្រូកពីរដំប និងមាន់បួនដប់សម្បុក ... ។

បង ហម មានអាយុ ៤០ឆ្នាំ ។ គាត់មានមាឌធំដំបង គាត់ជាទាហានជើងក្របមចាស់ ។ គាត់បានឈប់ធ្វើទាហានតាំងពីឆ្នាំ ១៩៤០ ។ មិត្តភ័ក្តិដែលធ្វើទាហានជាមួយគាត់ច្រើននាក់ ក្រោយពីចេញពីទាហាន បានធ្វើភ្នាក់ងាររាជការ ។ ខ្លះបានធ្វើចីពេទ្យ ខ្លះបានធ្វើចីមេព្រៃ ខ្លះទៀតបានធ្វើស្មៀន ... ។ ឯចំណែកបង ហម គាត់បានធ្វើកូននាម៉ឺនតូចក្នុងគ្រាវ្ទីដែរ គាត់ធ្វើកាប៉ូរ៉ាលត្រួតផ្ទាល់គរពាមក្បែរផ្ទះគាត់នេះ ។ ជាប់ជិតប្រាំឆ្នាំហើយ គាត់បានឈប់ធ្វើនាម៉ឺន ព្រោះគាត់បានប្រកែកនឹងមេការបារាំង ដែលបានបន្ទោសគាត់មិនសមហេតុមិនសមផល ។ កាលនៅពេលទាមទារ តស៊ូ ដេញបារាំង បង ហម បានធ្វើជីវពល ។ ដោយធ្លាប់បានធ្វើទាហានជើងក្របម គាត់ក៏បានឆាប់ចេះមួយពីរ ឆ្វេងស្ដាំ ត្រឡប់មុខ បែរក្រោយមុខអ្នកភូមិ ដូចនេះគាត់ក៏ត្រូវតាំងជាមេកងជីវពល ។ ក្នុងខណៈនោះ ដូចអ្នកភូមិគាត់ភាគច្រើន គាត់បានខ្ចីលុយគេកាត់ខោអាវគគីរ ស្បែងជើងឃ្លុប និងទិញកាំភ្លើងឈើមួយ ។ ស្រុកបានសន្តិភាព គាត់ក៏បានច្បាប់ទទួលកាន់កាំភ្លើងមួយពីសាលាស្រុកដើម្បីការពារភូមិគាត់ ។

អ្នក សន ប្រពន្ធគាត់ ជានារីមួយរូបឆ្នើមក្នុងការរកស៊ី ។ ក្រៅពីធ្វើស្រែ គាត់បានឆ្លៀតលក់ទៀត ។ រាល់ព្រឹកគាត់បានក្រោកពីមាន់រងាវ ផ្ទុកអង្ករដាក់ឡានយកទៅលក់ឯចំការទល់ពេលត្រង់ជាក់ បានមកផ្ទះវិញ ។ រាល់រសៀលម៉ោង ២ គាត់ទៅអុំស្ទៃអង្ករ នៅម៉ាស៊ីនស្រូវខាងកើតថ្នល់ទល់ព្រលប់ មើលគ្នាមិនស្គាល់បានមកផ្ទះ ។

ថ្ងៃនេះនៅពេលម៉ោង ៤ ជាង ម៉ាស៊ីនកំពុងតែដើរញាប់ហើយ អ្នក សនកំពុងតែញើសជោកអុំស្ទៃប្រមូលអង្ករ មីកូនបងពូព្រឿង បានរត់ទៅដល់ស្រែកហៅថា ...
" មីង សនៗ មានគេរកនៅផ្ទះ " ។

អ្នកណាឱ្យហៅ ហាង " អ្នក សន បានសួរ "

- ខ្ញុំមិនស្គាល់ទេ ឪខ្ញុំឱ្យហៅ ឆាប់ មក ទៅ

អ្នក សន បានខំបោសជជុះកន្ទក់ និងអង្កាមចេញពីខ្លួនរួចកាលណា ក៏ខំដើរយ៉ាងញាប់ទៅផ្ទះគាត់ ។ ដល់ផ្ទះ គាត់ មនុស្សពីរនាក់ ប្រដាប់សម្លៀកបំពាក់ជាប៉ូលិស និងពូព្រឿងដៃមួយខ្ទប់ភ្នែកបានឈរនៅជាមួយ ។ ឃើញអ្នក សន ទៅជិតដល់ ប៉ូលិសម្នាក់កេះថី ដោយជម្រាបថា :

- ប្រពន្ធអាហាមដល់ហើយ ។

អ្នក សន ក៏បានសួរទៅភ្នាក់ងារប៉ូលិសដែលនិយាយនោះថា :

- លោកបង មុយ ឯងអញ្ជើញរកអី

- លោកចៅហ្វាយឱ្យមកហៅ អាហាម

- ប្ដីខ្ញុំគាត់មិននៅទេ មានការអីរកគាត់

- ឃើញទេ មុយឯង គ្រាន់តែនាំខ្លួនវាពីព្រឹកមិញជាមួយកាំភ្លើងទៅមិនបានទេ ទាល់តែគេចបាត់ បានមករក ។ ... លោកចៅហ្វាយកិនងាប់ហើយអញមិនដឹងទេ ថីដោយបានកិន ។

- លោកស្មៀន ហ៊ុន បានប្រើខ្ញុំឱ្យមកហូតកាំភ្លើង ។ ខ្ញុំហូតយកទៅដល់សាលាស្រុកបានលោកថា ឱ្យនាំអាហាមទៅ មិនមែនខុសពីខ្ញុំទេ ។

ចីដោយបានចោលភ្នែកទៅ ...លើតុពោរពេញដោយកាសែតប្រជាធិបតេយ្យ សាមគ្គី ...ក៏លាន់មាត់ថា

- មើលកាសែតម្លឹងៗ បានជាពូកែដោះស្រាយណាស់

- ខ្ញុំបានមកដាស់តឿនពន្យល់វាពីរបីលើកដែរ ប៉ូលិសមុយបានឆ្លើយ ។ វាត្រឡប់ជាគិនខ្ញុំវិញ ។ វាថាកុំឱ្យខ្ញុំល្មើពកថ្វាសកាន់ក្បួនប៉ូលិស ទាហានបារាំងដើរសម្លុតជីកស្រាមិនឱ្យលុយគេទៀត ។ វាថាវាដឹងខ្លួនហើយ ។ វាពន្យល់ខ្ញុំថា អាមេរិចកាំង មេបង្កើតម៉ាស៊ីនស្រូវធំស្រុកយើងនេះ ខូចណាស់ ចង់អូសទាញខ្មែរឱ្យខ្ញុំវាទៀត ។

- បើដឹងដូចនេះ ហេតុអ្វីក៏ប៉ូលិសមុយឯង មិនប្ដឹង ចីដោយគិន ។

- ប្ដឹងឯម៉េចបាន ។ បើលោកចៅហ្វាយជាប់ដៃជាមួយវា ។ ទៅគរក៏ហៅវាទៅដែរ ហើយបែបផ្អែកលើវាជាងខ្ញុំ ។

- លោកចៅហ្វាយណា

- លោកមុន

- ឈប់ជជែក យើងត្រូវរកហាម ។ ចីដោយបានឃាត់រួចបើកភ្នែកមើលមុខអ្នកសនស្ទួរដោយពាក្យធំៗថា :

ប្ដីទៅណាប្រាប់មក កុំលាក់

- ខ្ញុំមិនដឹងទេ ខ្ញុំមកពីលក់អង្ករវិញមិនឃើញគាត់ ។

ក្រែងនៅពួនក្រោមផ្ទះបាយទេ បើដូចនេះខ្ញុំចូល ថាចប់ចីដោយបានដើរចូលកាត់ផ្ទះទៅក្រោយបើកវាំងននឈ្ងោកមើលក្រោមគ្រែមិនឃើញ ហួសទៅផ្ទះបាយ រួចបកត្រឡប់កាត់ល្វែងពូព្រៀង ឈ្ងោកមើលកៀនៗទៀត ។

ប៉ូលិស មុយ និងចីដោយបានឈ្ងោកមើលគ្រប់មិនឃើញ ក៏បបួលគ្នាចេញទៅវិញ ។ អ្នកផ្ទះជិតខាងបានផ្អើលមើលឈ្ងូនរ ឯចំណែកផ្ដែ ក៏បានព្រុសសន្ធាប់យ៉ាងខ្លាំងដេញពីក្រោយ ... ។

# ២. ខ្សឹកខ្សួល

បន្ទាប់ពីប៉ូលិសទៅភ្លាម អ្នកស្រុកដែលបានឃើញព្រឹត្តិការណ៍នេះ បាននិយាយខ្សឹបប្រាប់គ្នាថា : គេរកចាប់ៗៗៗ ... ។

ដំណឹងនេះបានចូលទៅដល់ម៉ាស៊ីនស្រូវមួយរំពេច ។ អ្នកធ្វើការនៅម៉ាស៊ីនបានស្រឡាំងកាំងគ្រប់គ្នាលាន់មាត់ស្ដីថា :

- គាត់មានរឿងអ្វី ?

- ម៉េចគេចាប់បានគាត់ វី នៅ ?

- អញបានហាមញឹកថា កុំឱ្យចេញមុខមាត់ពេក វាមិនស្ដាប់អញសោះ ទាល់តែអីចឹង ... ។

នាងសុន ក្ដួយបងហាមនិយាយដាច់ថា :

គេរក ... គេរក ... គេរកចាប់ពូមែន

- ប៉ូលិសមុយ និងចីដោយមករកចាប់ទើបតែចេញផុតទៅវិញ "ពូព្រឿងបានប្រាប់" ពូមានរឿងអ្វី ?

- នៅតែមិនដឹងទៀតហាងឯង "ពូព្រឿងបានឆ្លើយបណ្ដើរ ដើរទៅល្វែងគាត់បណ្ដើរ" ។ ពូហាងគ្មានរឿងអ្វី ពីនយោបាយទេ ។ ក្រហមវាមិនទៅលួចប្លន់ កាប់នរណាឡើយ ។

ស្រីទាំងពីរនាក់នៅឈឹងគ្មានចេញស្ដី មុខខ្មៅអែរ ។ អ្នកសនអង្គុយលើគ្រែជាប់ជញ្ជាំងកណ្ដាល ។ គាត់មើលរូបថតបងហាមព្យួរនៅជញ្ជាំងក្បែរនោះ ។ នាងសុនទឹកភ្នែកហូរល្ហាមញ័រដៃខម្រើកបានហូតធូបបីសរសៃ អុជរួចយកទៅដោតនៅក្បែរកញ្ចក់ព្រះពុទ្ធរូប ។ នាងនិយាយជិបអួចៗថា :

សូមលោកយាយចាស់ស្រុកជួយខ្ញុំផង ... ។ សូមកុំឱ្យគេចាប់គាត់បាន ... ។

ឃើញស្រីៗយំព្រួយដូចនេះ ពូព្រឿងក៏បានត្រឡប់ចេញពីល្វែងផ្ទះគាត់ ហើយដើរចូលមកអង្គុយលើគ្រែជិតអ្នក សន ។ គាត់និយាយថា :

- មិនដឹងជាព្រួយខ្មោចអីទេ ក្រហមវាមិនស្លាប់ទេ

- ខ្មាសគេណាស់ ពូជខ្ញុំមិនដែលជាប់គុកទេ "នាងសុននិយាយរអាក់រអួលទាំងទឹកភ្នែក"

- អញមិនគិតពីពូជទេ តែអាណិតស្ដាយពូហាងណាស់ ។ តាំងពីប្រសព្វគ្នាមក ពូហាងមិនដែលល្អនឹងអញដូចឆ្នាំនេះទេ ។ កាលឆ្នាំមុនៗ ផ្ដេសផ្ដាសដើរតែស៊ីផឹក ។ តាំងពីឈប់ធ្វើការមកគិតតែពីអាវាសែ បន្តិចតាមលោកនេះ បន្តិចមានស្រីជាមួយលោកនោះ កន្លះខែបានអើតផ្ទះម្ដង ... ។ តែតាំងពីបងសែម ភូមិឯជើងមកលេងផ្ទះញឹកមាហាងបានប្រែឈប់ទៅកំពង់ បានឃ្លាតឆ្ងាយពីអស់លោកខ្លះ ... ។ អញឃើញគាត់បានមើលសៀវភៅតូចៗ ហើយចេះគិតប្រពន្ធកូន ផ្ទះសម្បែង ... ។ គាត់ចេះជួយរកស៊ីយើង ។ ពេលព្រឹកៗគាត់មានឆ្លៀតទៅជួយលើកអង្ករយើងទៀត ។

- ពូ ចម្លែកមែន ។ គាត់កែប្រែច្រើនឥឡូវ " នាងសុនកាត់ " គាត់បានដាស់តឿនយើងឱ្យរៀនអក្សរ ។

- ក្ដារខៀននៅជញ្ជាំងខាងជើងនេះ គាត់បានខំឈ្លូសធ្វើជាមួយបងសែមពីអាទិត្យមុន ។ គាត់គិតពឹងអ្នកប្រពន្ធលោកគ្រូវ៉ាតឱ្យមកបង្រៀនស្រីៗ នៅភូមិយើងនេះ ។ មីក្សុន ឯងបានចេះមើលរួចខ្លះ ក៏ដោយសារតែពីមាហាងដែរ ។

- ឥឡូវខ្ញុំចេះកត់ត្រាបញ្ជីអង្ករចេញចូលខ្លះបានហើយ ។ ខ្ញុំបានមើលកាសែតដាច់ខ្លះ ហើយបានដឹងរឿងរ៉ាវស្រុកទេសខ្លះ ។

- មនុស្សល្អ មនុស្សគួរឱ្យស្រឡាញ់ បែរជាមានរឿងទៅវិញ " អ្នកសនបានឱ្យកខ្វល " ។ កាលខិលកាលផឹក កាលមានស្រីជាមួយលោកនេះ លោកនោះបាត់ៗពីផ្ទះទៅកំពង់ គ្មាននរណាជួយប្រដៅឡើយ ... ។ ស្រវឹងទាស់វាយពូហោងនៅផ្លូវបំបែក ក៏ប៉ូលិសមុយមិនរវល់ មានតែចាក់ស្រាថែម មានតែបបួលទៅកំពង់ ។ នេះ

បានចំ ... ។ ឃើញប្ដីឯងគ្រាន់បើជួយធ្វើការឯង គាត់មកពង្រាត់យកពីឯងទៅ ។ ស្រុកគេអីចេះទេលោកអើយ ខ្ញុំមិនដែលឃើញទេ អញចង់តែស្រែកឱ្យបែកភូមិផ្អើលឥឡូវ ... ។

- កុំឱ្យីកខ្សួលច្រើនពេក សនអើយ ។ "ពូព្រឿងបានទូន្មាន" ។ ណើ្ហយកុំយំស្រែកច្រើនពេក ល្មមរកដាំបាយស៊ីទៅយប់ហើយ ។

ថារួចគាត់ក៏ចេញទៅផ្ទះគាត់ ។ ឯចំណែកអ្នកសននៅអង្គុយនឹងកន្លែងដដែល ។ មួយសន្ទុះក្រោយមក គាត់ក៏បានដើរចូលទៅក្រោយ ។ នាងសុនប្រញាប់ប្រញាល់ បានត្រឡប់ទៅយកល្អី កញ្ច្រែងពីម៉ាស៊ីនវិញ ... ។

# ៣. ជួយគ្នាទាន់គ្រាក្រ

ក្រោយពីពេលប៉ូលិសមុយដកហូតកាំភ្លើងទៅវិញ បងហាមបានពិភាក្សាជាមួយពូព្រឿង បានមូលមាត់គ្នាថាត្រូវតែដកខ្លួនចេញពីមុខមាត់គេសិន ។ ដោយហេតុនេះហើយបានជានៅល្ងាចថ្ងៃរសៀល ប៉ូលិសមុយ និងចឺដោយទៅរកគាត់មិនឃើញ ។ បងហាមបានទៅនៅផ្ទះលោកគ្រូម៉េង នៅភូមិដើមពោធិ៍ខាងត្បូងម៉ាស៊ីនស្រូវធំ ។ គាត់ទៅនៅសំណាក់ផ្ទះថ្មីនេះ គ្មាននរណាមួយនៅផ្ទះគាត់ដឹងឡើយ ។ ពូព្រឿងក៏មិនដឹង អ្នកសនប្រពន្ធគាត់ក៏មិនដឹង ។

ដំណើងប៉ូលិសមុយ និងចឺដោយចូលទៅកកូរក្នុងផ្ទះរកចាប់ បងហាមបានឱ្យលោកគ្រូម៉េងនៅមិននឹង ។ គាត់បានទៅឱ្យប្រាប់លោកគ្រូច័ន្ទឱ្យមកជួបបងហាម ។

លោកគ្រូច័ន្ទមានរាងស្គមឆ្អឹង ។ សក់គាត់រួញអង្កាជី ។ គាត់មិនមែនជាមនុស្សឡូឡាច្រងេងច្រងាងទេ ។ គាត់និយាយតិចៗញឹមៗ ។ គាត់បានចេះដឹកនាំអប់រំគ្រូនៅស្រុកគាត់ឱ្យស្គាល់តម្លៃប្រជាជនអ្នកស្រែ ទាល់តែគ្រូៗស្ម័គ្រចិត្តឡើងប្រក់ដំបូល ធ្វើជញ្ជាំងសាលា ហើយហ៊ានបរិច្ចាគលុយផ្ទាល់រាល់ខែ ជួយពង្រីកសមាគមសាលារៀន ។ គំនិតមារយាទឬកពាគាត់បានទទួលសេចក្ដីរាប់អានស្ទើរគ្រប់ប្រជាជន ។ លោកគ្រូម៉េងជាស្មៀននៅមន្ទីរចាត់ការសាលារៀន ។ ការរាក់ជ្រៅគាត់មើលមិនសូវឃើញច្បាប់លាស់ប៉ុន្មានទេ ។ គាត់រាប់អានបងហាម ហើយគោរព និងស្រឡាញ់លោកគ្រូច័ន្ទណាស់ ។ មានការអ្វីចម្លែក ឬទ័លគំនិតមើលអ្វីមិនឃើញ គាត់ច្រើនបបួលគ្រូៗឯទៀតទៅបាយទឹកឯផ្ទះបងហាម ។ ការប្រជុំគ្នានេះ គេច្រើនតែចំអែចំអន់និយាយដាក់ផ្លែផ្កាឱ្យគ្នា... ។ តែធម្មតាមុនបាយ ឬក្រោយបាយគេច្រើនតែជជែកគ្នាពីនយោបាយក្នុងស្រុក ក្រៅស្រុក និងពីមធ្យោបាយដែលគេត្រូវដើរ ដើម្បីពង្រីកសាលារៀនក្នុងភូមិ ។

នៅក្នុងការតានតឹងរកចាប់ចងបងហាមដូចនេះ លោកគ្រូម៉េងបានទៅស្នើលោកគ្រូច័ន្ទ សម្រេចថាត្រូវជួបគ្នា ។ លោកគ្រូម៉េងបានទៅពេលព្រលប់ងងឹត នាំបងហាម

ឡើងទៅលើឡៅផ្ទះមួយសង់មិនទាន់ហើយ ទល់មុខផ្ទះលោកគ្រូវ៉ាត ។ មួយសន្ទុះក្រោយលោកគ្រូច័ន្ទមកដល់ ។ គាត់បោសអង្កាច់ដែកឈូស ហើយបបួលគ្នាដំកង់ពែនភ្នែន ។ បន្ទាប់មកគាត់ហូតបារីកញ្ចប់ខៀវដែកកេះដាក់កណ្ដាលវង់ រួចញញឹមៗមើលមុខបងហាម ស្ដីថា :

- ម៉េចយើង គេរកចាប់មែនទែនហើយ ថ្ងៃនេះបងឯង ។ ថ្ងៃមុនម៉ៅ ថ្ងៃក្រោយមុខជាវេននរណាទៀតហើយ ។

- តើលោកគ្រូគិតដូចម្ដេចចំពោះរឿងខ្ញុំ? មានរឿងអ្វីថ្មីទៀតទេ "បងហាមសួរ"

- មានតែពីការចាប់ចងនឹង" លោកគ្រូម៉េងឆ្លើយ" ពីម្សិលមួយ នាយអេងភូមិខាងជើងបានត្រូវចាប់ ។ គេដាល់គ្នាពីរបីដៃបែកឈាមលើប្រជុំចិញ្ចើម រួចហើយចងស្លាបសេកគ្នាបណ្ដើរយកទៅសាលាស្រុកដាក់ខ្នោះជើងនៅបៀតខ្លោងទ្វារចូល បង្អត់បាយថ្ងៃត្រង់មួយពេល ។ ព្រឹកបន្ទាប់បានគេដាក់ខ្នោះដៃបញ្ជូនទៅសាលាខេត្ត ... ។ ឯចំណែកលោកគ្រូច័ន្ទក៏មិនដឹងជាដូចម្ដេចដែរ ។ តាមលោកគ្រូផាន់ប្រាប់ខ្ញុំថា ដល់រួចរាល់ចូលកងទៅវិញ លោកគ្រូឯងមិនបាននៅស្រុកយើងទៀតទេ មុខតែស្ទឹងត្រែងក្រចេះហើយ ។ គេប៉ងចាប់ដែរតែចាប់មិនកើតព្រោះទាល់តែបានអនុញ្ញាតពីរដ្ឋមន្ត្រីសិន ... ។

- មិនមែនតែស្រុកយើងទេ មានការចាប់ចងនោះ "លោកគ្រូច័ន្ទបានកាត់" ។ នៅកោះសូទិន មេមត់ ជប់ ស្គន់ ចំការលើ ស្វាយរៀង ខេត្តកណ្ដាល ...ក៏សុទ្ធតែមានការចាប់ចងដែរ ។

- បើដូចនេះ ខ្ញុំត្រូវធ្វើដូចម្ដេច ? ខ្ញុំត្រូវទៅផ្ទះវិញឱ្យគេចាប់ទៅឬ? តាមខ្ញុំៗចង់ឱ្យគេចាប់ឱ្យហើយទៅ តើខ្ញុំមានរឿងអ្វី ? " បងហាមបានសួរ"

- មិនចាំបាច់មានរឿងទេ ? មនុស្សពីរបីនាក់ប្តិតមេដៃប្តឹងភ្លាមទៅគេចាប់បងហាមឯងបានស្រេច ហើយតែដល់គុកគេឃុំបំភ្លេចចោល ឃើញទេអាហ៊ាននៅឯកើតថ្កល់នោះ ជាប់គុកទទេជាង ២ឆ្នាំ ទើបតែគេដោះលែងពីខែមុន ... ។ " លោកគ្រូម៉េងឱ្យយោបល់"

- ចុះបើយើងគេច គេមិននិយាយថាយើងមានរឿងមានខ្លួនហើយៗម្យ៉ាងទៀត អ្នកភូមិយើង មិនថាយើងត្រចៀកសទៅហើយ មិនទាន់បានអីផងចោលស្រុកដាយបាទជើងសព្រាតទៅហើយ ... " បងហាមបានចោទ "

- ចុះបើយើងជាប់គុកវិញបានផលអ្វីខ្លះ ? តាមខ្ញុំៗថាគ្មានបានអ្វីក្រៅពីអ្នកប្រពន្ធបងព្រួយ ហើយក្រៅពីពួកយើង ពិបាករៃលុយជូនបាយឱ្យបង ... ។ តាមដែលយើងបានដឹង បានប្រទះខ្លះ ឃើញថាជួនកាលគេកំញើញឬចាប់យើងយកទៅគ្រាន់តែរកលុយ ។ ដូចរឿងនាយអេងនេះជាការច្បាស់ណាស់ ។ ម្ដាយគាត់បានមកជួបខ្ញុំ ហើយពឹងឱ្យខ្ញុំជួយរកចងការប្រាក់គេ ២០០០រៀល ដើម្បីដោះកូនគាត់ គាត់ថាលោកកាន់រឿងនេះ បានខ្សឹបប្រាប់គាត់ថា កូនគាត់ត្រូវគេចោទ លាក់កាំភ្លើង តែគេអាចជួយឱ្យនៅក្រៅឃុំបាន បើកាលណាយើងរកប្រាក់ ២០០០រៀលទៅឱ្យគេ ... ។ ឃើញទេនរណាមិនដឹងថា នាយអេងគ្មានរឿងអ្វីគ្រាន់តែគ្នាដេញដោលពូជា នៅគរពីអាទិត្យមុន ... ។ ចំពោះបងហាមនេះតាមយោបល់ខ្ញុំ យើងត្រូវតែកុំចេញមុខ យើងត្រូវសម្ងំសិនស៊ើបពិនិត្យភេទការណ៍ឱ្យជាក់លាក់ តើរឿងអ្វីដែលគេរកចាប់យើង ។ តើបង្គាប់មកពីលើ ឬគ្រាន់តែគ្នាឯងក្នុងស្រុកទេ ? បើពីលើយើងមិនងាយរួចទេ តែបើគ្នាឯងក្នុងស្រុកវិញ យើងគេចទៅមួយខែពីររួចខ្លួនហើយ តើលោកគ្រូម៉េងយល់ថាម៉េច?

- ខ្ញុំយល់ស្របពេញទី ។ តែខ្ញុំយល់ថាឱ្យពូហាមនៅផ្ទះយូរទៀតមិនបានទេ ។ មិនស្ងាត់មិនជិតទេ ត្រូវបណ្ដោះទៅឆ្ងាយ ... ។

លោកគ្រូច័ន្ទគិតមួយស្របក់ឆ្លើយ :

- បងទៅឆ្ងាយពីស្រុកយើងសិនទៅ ។ ដល់ពេលស្រួលចាំអញ្ជើញមកវិញ ... ។

បងហាមក៏សុខចិត្ត ។ លោកគ្រូច័ន្ទបានហុចបារីទៅបងហាម រួចអុជឱ្យ ។ បន្ទាប់មកគាត់ក្រោកឈរមុនគេ ចុះមកដីទៅផ្ទះគាត់ ។ លោកគ្រូម៉េងបានចុះតាមឃើញស្ងាត់ក៏ហៅបងហាមឱ្យចេញទៅផ្ទះវិញ ... ។

# ៤. គាត់វាលស្រែពេលយប់

ក្រោយពេលប្រជុំគ្នាបានមួយថ្ងៃ នៅពេលយប់ងងឹតមើលគ្នាមិនស្គាល់ លោកគ្រូម៉េងបានជូនបងហាមទៅផ្ទះអាចារ្យសម នៅខាងលិចដើមពោធិ៍ ។ ផ្ដាំផ្ញើសព្វគ្រប់រួចកាលណា លោកគ្រូម៉េងត្រឡប់មកវិញ ។ ឯចំណែកបងហាម អាចារ្យសមក៏បានបណ្ដើរគ្នាចេញទៅទៀត ។ អ្នកថ្មើរជើង ទាំងពីរនាក់ដើរយ៉ាងលឿនមិនបានផ្លាស់ប្ដូរសម្ដីរកគ្នាទេ ។ គាត់ដើរឱ្យឆាប់ដល់ ដើម្បីឱ្យផុតពីមុខមាត់ប៉ូលិស ឱ្យឆាប់ឃ្លាតឆ្ងាយពីផ្លូវថ្នល់ ។ កន្លះម៉ោងក្រោយគាត់ទៅដល់ភូមិប្រាសាទ ។ ចេញផុតផ្លាក្រោយភូមិជិតដើមចំបក់ គាត់ឃើញស្រមោលមនុស្សមួយស្ទុងបានដើរចេញទៅ ។ បងហាមទុចអង្គុយក្រាបចុះ ។ អាចារ្យសមបានដើរទៅទៀត ។ ជិតដល់ស្រមោលនោះគាត់ក្អកគ្រហែមស្រែកហៅថា :

- អាដែងអើយមកទៅផ្ទះ យប់ងងឹតណាស់ កុំនៅយូរពេក ។

ស្រមោលមនុស្សស្ទុងបានទុច ហើយស្រែកឆ្លើយថា

យីលោកពូទេ អញ្ជើញទៅណា ?

អញស្មានតែខ្មោចលង ។ ខំសូត្រយថាមួយចប់ពីរទៅហើយមិនដឹងជាខ្មោចអន្ទិតឡើងសោះ ។ ម៉េចទៅណាទាំងយប់ដូចនេះ ?

- ទៅភូមិឫស្សី ទៅសួរបងខ្ញុំឆ្លងទន្លេ ...
- បងអន្ទិតឡើងណាមួយ ?
- បងឡេងណា
- វាបានកូនស្រីឬប្រុស ?
- ប្រុស
- អន្ទិតទៅតែម្នាក់ឯងទេឬ ?

- ចុះចាំបាច់នរណាជូន

- ឮអន្ទិតឡឹងដូចនេះ បងហាមក៏ដើរចូលមកបៀតហើយនិយាយថា :

- អញស្មានតែមិនមែនអ្នកឡឹងឯង

- យីលោកបងហាមទេតើ សុខ្ខតែគ្នាឯងម្តង ... ។ ឮថាគេរកចាប់ បងម៉េចទៅឥឡូវ ។

- វាគ្មានការអ្វីជាធំដុំទេ ។ កុំព្រួយធ្វើអ្វីអ្នកឡឹងឯងទៅណា ?

- ខ្ញុំទៅភូមិឫស្សី

- នៅឯណាទៅភូមិឫស្សី ?

នៅតែធ្វើពើមិនស្គាល់ទៀត ភូមិដែលយើងទៅពីខែមុននោះ ... ។

- ភូមិដក់គាំនោះឬ ?

- ហ្នឹងហើយ

- បើដូចនេះយើងត្រូវផ្លូវគ្នាហើយ ។ តស់យើងដើរទៅជាមួយគ្នា ... ។ ដល់អូរចាំយើងបែកគ្នា ។

អ្នកដំណើរបានបន្តដំណើរទៅ ។ បងហាមបានចាប់សួរ

- ម៉េចអ្នកឡឹងមានផ្លូវទេ ភូមិឫស្សី បងប្អូនយើងសុខសប្បាយទេ ?

- សុខតែមិនសប្បាយទេ ដូចលោកបងឃើញហើយគ្នាក្រណាស់ សព្វថ្ងៃនេះគ្មានបាយសុខ្ខស៊ីទេ គ្នាស៊ីបាយលាយពោត ។

- ភូមិឫស្សីបានបើកភ្នែកខ្ញុំឱ្យឃើញទុក្ខវេទនារាស្ត្រ ម៉ៅស្រលាញ់អ្នកភូមិនេះណាស់ ។

- អើម៉េចទៅលោកគ្រូម៉ៅ " ឡឹងបានសួរ" ខ្ញុំឮគេចាប់គាត់ ខ្ញុំញ័រខ្លួនអាណិតគាត់ជាពន់ពេក គេមានវាយដាក់ខ្នោះទេ ... ។

- ខ្ញុំមិនសូវបានដឹងដែររឿងនេះ ព្រោះខ្ញុំបានឈប់ជួបគាត់ជិតមួយខែ តាំងពីពេលក្រោយត្រឡប់ពីភូមិនេះទៅ ... ។ បានដឹងថាសព្វថ្ងៃគាត់ជាប់គុកនៅកំពង់ ... ។

- នេះបានចំ ខ្ញុំចូលចិត្តគាត់ណាស់ អ្នកភូមិឫស្សីសរសើរគាត់គ្រប់មាត់ ។

អាចារ្យសមបានកាត់ :

- មើល៍ហាមឯងបាននិយាយថាភូមិឫស្សីបានបើកភ្នែកខ្លួន តើមានអ្វីខ្លះ ? ខ្ញុំនៅជិតភូមិនេះដែរតែដូចជាវាមិនឃើញមានអ្វីខុសគេ ?

- លោកបង អាចារ្យមិនដែលទៅបានជាអីចឹង ។ កាលពីខែមុនខ្ញុំ និងប្អូនម៉ៅព្រមទាំងគ្រូៗ ប្អូនប្រាំនាក់ទៀតជិះកង់លើថ្លីទៅភូមិនោះ ។ អ្នកស្រុកក្រហៅមហាក្របានទទួលយើងដូចស្គាល់គ្នា ប៉ុន្មានឆ្នាំមកហើយអីចឹង ។ គេនិយាយប្រាប់យើងគ្រប់ ។ គេមិនដែលបានស្គាល់នាម៉ឺនមកភូមិគេទេ ។ រាល់ឆ្នាំគេមានរឿងតែជាមួយមេសៃវៀនបឹង ។ បងអាចារ្យដឹងទេ មេសៃវៀនបឹងបានចាត់អ្នកលេងប៉ាវកេបឹងឱ្យមកលើកមកកាប់ទ្រូ កាប់លបអ្នកស្រុក ។ ថៅកែបឹងមានអ្នកលេងកាប់ៗចាក់ៗសម្លុតអ្នកស្រុក ដែលដាក់ទ្រូដាក់លបបន្តិចបន្តួចគ្រាន់និងចិញ្ចឹមឆ្នាំង ។ ថៅកែបឹងរំលោភអស្ចារ្យហើយគេបានប្រកាន់ថាបឹង គេមានព្រំត្រឹមត្រូវទឹកឡើងរហូតមកដល់មាត់ភូមិក្នុងស្រែ អ្នកស្រុក... ។ រាល់ឆ្នាំអ្នកភូមិត្រូវមេសៃវៀនធ្វើបាប ហើយអ្នកលេងបឹងនោះកាចសាហាវមានអំណាចអស្ចារ្យ គេអាចសម្លាប់អ្នកភូមិបានគ្មានទោស ។ គេបង្វែងដានបានទាំងអស់ ។ ថៅកែគេបានស្គាល់អស់លោកនាម៉ឺននៅខេត្តស្រុកស្រេច ... ។

- ខ្ញុំគ្មានដឹងសោះ " អាចារ្យសមលាន់មាត់"

- លោកបងអាចារ្យដឹងម៉េចកើត បើរវល់តែស្ថានទេវតាឯណាឯនោះ ត្រូវគិតការរស់នៅលើដីផង... ។ កុំគិតតែភាវនាមូសខាំឈឺជិតងាប់មិនហ៊ានទះនោះ ផ្លូវនោះបងវើនខ្ញុំលែងដើរហើយ ។

- យើងគិតដូចម្ដេចជួយដោះទុក្ខអ្នកភូមិនោះផង " ឡឹងមានចោទ" ។

ការដោះទុក្ខកែប្រែការរស់នៅពិបាក ហើយយូរផង ។ យើងមិនអាចពិភាក្សាគ្នាដែរផងទេ ព្រោះយើងដល់ផ្លូវបែកគ្នាហើយ ... ។

- យើងឈប់និយាយគ្នាមួយស្របក់ទៅ យើងកំពុងតែជក់មាត់ "ឡឹងបានស្មើ"

- ឈប់ក៏ឈប់ "អាចារ្យសមយល់ព្រម" តស់យើងទៅឈប់នៅមាត់អូរ ... ។

អ្នកទាំងបីបានឈប់ ។ ឡឹងបានអង្គុយមុនគេ ។ អាចារ្យសមបានជក់បារី បងហមបានបត់ជើងតូចរួចក៏ត្រឡប់ទៅអង្គុយជាមួយគេ ។ បន្ទាប់មកគាត់ចាប់និយាយ :

... ការដោះទុក្ខកែប្រែការរស់នៅប្រជាជនយើងគ្រប់គ្នា ជាការពិបាក ជាការយូរមិនឆាប់ដូចមាត់ទេ ។ ព្រោះមនុស្សធ្វើមិនមែនទេវតាឯណាធ្វើជួសយើងទេ ... ។ យើងត្រូវអប់រំខ្លួនយើង និងអប់រំអ្នកភូមិឱ្យយល់ ជឿលើកម្លាំងខ្លួន ហើយឱ្យដឹងថាទាល់តែយើងរួមកម្លាំងសាមគ្គីគ្នាបានយើងអាចនឹងទប់ទល់នឹងអ្នកលេងដៃជើងថៅកែមេសៃវៀនបាន ។ នៅស្រុកស្រែជាមួយយើង វាអាងអ្នកលេង នៅទីក្រុងវាអាងនឹងទឹកប្រាក់ ... ។ បើដូចនេះ បើចង់រួចខ្លួន ចង់បានស្រួល ចង់បានយុត្តិធម៌ ទាល់តែអ្នកភូមិនេះចេះបង្រះកែប្រែខ្លួនឡើង ។ ការរៀបចំភូមិឃុំ ជាការចាំបាច់ មុនគេបង្អស់ចំពោះក្រុមយើង ។ ដោយហេតុនេះ បានជាខ្ញុំយល់ឃើញថាដល់រួចរាល់ ឆ្នាំក្រោយៗនេះ យើងត្រូវតែឱ្យមានសិទ្ធិប្រជាជនបោះរើសនាយកឃុំ... ។ តែនាយកឃុំយើងមិនមែនមានភារៈតែដើរជិះជាន់សង្កត់សង្កិនរាស្ត្រ ដូចអាណានិគមនិយមបាំងបង្កបង្កើតនោះទេ ។ នាយកឃុំយើងជាតំណាងប្រជាជននៅឃុំ ហើយមានភារៈកែប្រែអ្នកភូមិពីក្តីវេទនាគ្មានអាវពាក់ ពីអំពើចោរកម្ម ពីការគំរាមកំហែង ។ យើងត្រូវមានគ្រោងការណ៍ដូចតទៅនោះ :

១. ខាងនយោបាយការពារ និងពង្រីកសិទ្ធិសេរីភាព លទ្ធិប្រជាធិបតេយ្យ ជាក់ស្តែងពិតៗឱ្យប្រជាជនអ្នកស្រែមានអំណាចបោះឆ្នោតជ្រើសរើសរបៀបគ្រប់គ្រងឃុំភូមិរបស់ខ្លួន ។

២. ខាងសេដ្ឋកិច្ច បង្កើតផ្នែកសហករណ៍ ឬសមាគមកសិករ នៅក្នុងភូមិ ឃុំការពារ ផលដំណាំ ពោត ស្រូវ ស្ករ កុំឱ្យពួកថៅកែហាងឆេងមកវាយបន្ថោក យក

ចំណោញកប់ក្តោង ដូចសព្វថ្ងៃ ។ ម្យ៉ាងទៀតខាងបឹង ព្រៃវិញ ប្រមូលប្រជាជនធ្វើសមាគមការពារផលធម្មជាតិទាំងនោះ ទុកចែកសម្រាប់គ្រប់គ្នាមិនឱ្យមេសៃរៀន ក្តាប់ចំណោញរាប់សែនយកទៅជួលអ្នកលេងឱ្យមកធ្វើបាបអ្នកភូមិដូចសព្វថ្ងៃនេះ ទេ... ។

៣. ខាងសង្គមកិច្ច ចាត់តាំងឱ្យមានផ្នែកសមាគមនារី សមាគមយុវជន សមាគមអ្នកស្រែចំការ បង្កើតផ្ទះពេទ្យ ... ។

៤. ខាងវប្បធម៌ ពង្រីក និងបង្កើតសាលារៀននៅគ្រប់ភូមិ គ្រប់វត្ត ឱ្យមានចំនួនគ្រប់គ្រាន់ ដើម្បីគ្រប់ក្មេងបានរៀនសូត្រ ។ បង្កើតសាលាបង្រៀនមនុស្សចាស់ប្រុស ស្រីមិនចេះអក្សរ ...ឧបត្ថម្ភលោកគ្រូបង្រៀនឱ្យជួយរៀបចំដាក់កម្មវិធីសិក្សារបៀបប្រជាធិបតេយ្យពិតប្រាកដ ។ បង្កើតបណ្ណាល័យទិញសៀវភៅឱ្យប្រជាជនខ្ចីមើល ... ។

- គ្រោងការណ៍នេះខ្ញុំពេញចិត្តណាស់ ។តែតើយើងធ្វើបានឬទេ “ឡឹងបានកាត់”

- បានប្រាកដជាបាន ។ គ្រាន់តែយូរ និងឆាប់ ។ កង់ប្រវត្តិសាស្ត្រសង្គមមនុស្សកំពុងតែវិលសំដៅទៅលទ្ធិប្រជាធិបតេយ្យប្រជាជន ហើយគង់តែចក្រពត្តិអាមេរិចកាំងមកបង្វែងតំរាមកំហែងខ្លាស់យើងគ្រប់គ្នាយ៉ាងណា ក៏ទប់មិនបានឡើយ ។ បើមិនឆ្នាំនេះឆ្នាំក្រោយ ។ បើយើងធ្វើមិនទាន់បានកូនយើងធ្វើ ។ បើកូនយើងធ្វើមិនសម្រេច ចៅយើងមុខជាសម្រេច ។ បើភូមិ ឃុំយើងធ្វើមិនទាន់កើត ក៏ភូមិ ឃុំផ្សេងទៀតធ្វើបាន ។

- សប្បាយហើយក្មេងជាន់ក្រោយ “ ឡឹងបានសាទរ” ខ្ញុំមុខតែទៅនិយាយប្រាប់អ្នកភូមិឫស្សីទាំងយប់នេះហើយ ។

- ខែវះហើយ តស់យើងទៅ ។ “ អាចារ្យសមបានបញ្ចប់” ។

រួចគាត់ក្រោកឈរ បងហាមក្រោកតាមក្រោយបំផុត ឡឹងក្រោកទៀត ។ អ្នកទាំងបីបានបែកគ្នា ឡឹងឆ្លងអូរទៅភូមិឫស្សី ។ អាចារ្យសម និងបងហាមដើរតាមដងអូរទៅត្បូងសំដៅពាម ... ។

# ៥. មនោគមវិជ្ជាផ្សេងៗ

កក្កដាបានឆ្លងផុត ។ សីហាចូលជាង ១៥ថ្ងៃ ... ។ បដាចាស់ខ្លះដែលបានចងសន្ធឹងទទឹងផ្លូវនៅទីប្រជុំជនបានត្រូវបណ្ដាច់ ។ ខ្លះទៀតបានត្រូវខ្យល់បក់រហែក ... ។ បដាថ្មីបានចងជំនួស ។ នៅផ្លូវបំបែកទៅពាម ទៅកំពង់ ទៅភ្នំពេញខាងត្បូងម៉ាស៊ីនស្រូវមុខផ្ទះបងហម ចម្ងាយប្រហែល ៥០០ម៉ែត បដាថ្មីមួយបានចងសន្ធឹងមានលំអដោយមនុស្សពាក់ខ្លួនភ្ជួរនង្គ័លទឹមមនុស្សពីរនាក់ ហើយនៅខាងមុខនង្គ័លទឹមមនុស្សនោះមានរូបមនុស្សស្លូចខ្ពស់ពាក់មុខប្រមោយដំរី ។ បដាថ្មីចម្លែកខុសពីបដាមុនបានចាប់ភ្នែកមនុស្សឱ្យទៅកកកុញមើល ។ អ្នកជិះឡានទៅភ្នំពេញ ក៏បានឃើញដែរ ។ បដាថ្មីនេះបានឱ្យអ្នកដំណើរ និងអ្នកភូមិមានយោបល់ខុសៗគ្នា ។ ខ្លះថាអញប្រាប់យូរហើយពួកវានេះហើយដែលជាពួកប្រឆាំងដុតក្បាលបញ្ជី និងត្រាមេឃុំ ។ ខ្លះថាបើមិនធ្វើដូចនេះខ្លះ ធ្វើដូចម្ដេចណើងបោសសម្អាតអាណានិគមនិយមបាន ។ ខ្លះថាពួកអាដំរីនេះហើយដែលឱ្យតំណាងរាស្ត្រមានអភ័យឯកសិទ្ធិធំពេក ។

ទន្ទឹមនឹងបដា ខិតប័ណ្ណជាច្រើនម៉ឺន សែន លានបានបាចសាចរាយពាសវាលពាសភូមិ ។ ខិតប័ណ្ណខ្លះស្រែកថា មានតែប្រជាជនអាចដោះទុក្ខប្រជាជនបាន ។ ខ្លះទៀតបានលាតត្រដាងបញ្ជាក់ថានារីឈ្មោះនេះ ឈ្មោះនោះជានារីខ្លាឃ្មោកមិនមែនជានារីក្លាហានទេ ។ ខ្លះបានស្រែកថារួបរួមសាមគ្គីប្រជាជនគ្រប់ជាន់ថ្នាក់ ប្ដេជ្ញាការពារសន្តិភាព ឯករាជ្យ ប្រជាធិបតេយ្យ ... ។

ពេលចេះតែហូរឆ្លង... ។ ១១កញ្ញាកាន់តែខិតមកជិត ។ ចម្បាំងបដានិងខិតប័ណ្ណមិនស្ងប់ស្ងល់ មិនគ្រប់គ្រាន់តាមបំណងទេ ។ នៅត្រង់ផ្លូវបំបែកទៅពាម ទៅកំពង់ត្រង់ទីប្រជុំជនច្រើននេះ សកម្មភាពសង្គម និងបក្សនយោបាយរឹតប្រញឹករឹតប្រញាប់ ។ បន្តិចមេក្រុស្រែកប្រាប់ថា អ្នកកំពង់មកឃោសនា ។ បន្តិចខិតប័ណ្ណព្រាចតាមដងផ្លូវអំពាវនាវអ្នកស្រុកឱ្យទៅស្ដាប់អ្នកភ្នំពេញ ។ បន្តិចក្បួនឡានទាហានស៊ីវិលតូចធំទៅពាម ។ បន្តិចមេឃុំ ប៉ូលិស មេកងភូមិឃុំបានទៅនិមន្តលោកសង្ឃ និងហៅប្រជាជនឱ្យមកសាលាស្រុក បន្តិចក្បួនឡានធំពេញដោយសិស្សហួសទៅកំពង់... ។ នៅស្រុក

ម៉ាស៊ីនស្រូវត្រូវការប្រជាជនមានស្ទើររាល់ថ្ងៃ ជូននៅសាលាស្រុក ជូននៅថ្នល់បំបែក ជូននៅទីវាលមុខម៉ាស៊ីនស្រូវធំ ... ។ ឃោសនាម្តងៗ សុទ្ធតែមានអ្នកបន្ទរ និងអ្នកប្រឆាំង ។ អ្នកស្របច្រើនបានលាន់មាត់ថា នេះបានចំជាពីរោះ ចំជាចេះនិយាយចំជាគិតប្រយោជន៍រួមមែន ។ គ្មានចាក់ដោតផ្លែផ្កាឱ្យគេទេ គិតតែប្រមូលរកសាមគ្គីពិត... ។ អាមេរិចកាំងប៉ងមកជួសបារាំងមែន ។ អញថាយូរហើយ ឥឡូវដូចអញស្មានមែន ... ។

ឯអ្នកប្រឆាំងក៏មិនមែនបើកមាត់ដែរ ។ ខ្លះខំផ្ទៀងស្តាប់កត់ទុក ហើយគ្រូះតេះដៀល ។ ខ្លះច្រឡោតខឹងរអ៊ូប្រាប់អ្នកនៅបៀតខាងថា : ... "ឃើញទេវានិយាយអួតតែពីសីណែរ" ។ វាថាការបោះឆ្នោតនេះសម្រេចមកពីសីណែរ មិនមែនបារាំងឱ្យបោះទេ ... ។ មើល៍វាថាកិច្ចព្រមព្រៀងយោធាខ្មែរអាមេរិចកាំងប្រឆាំងបំផ្លាញអាព្យាក្រឹត្យឃើញទេ វាចោទរដ្ឋាភិបាល ... ។ អញផ្ចិតមេដៃ ប៉ិ្ដងចាប់ដាក់គុកហើយ ... ។

មានខ្លះទៀតមិនខ្ចីស្ដាប់ មិនខ្ចីឮ ។ ពួកនេះច្រើនជាប់មាត់នឹងឪទិន ។ គេដាក់មួយចានហើយមួយចានទៀតអស់ស្រែះមួយហើយស្រែះមួយទៀត ។ អស់ចិត្តដល់ព្រះអង្គគេកាលណា គេបញ្ចេញឥទ្ធិពលសាហាវគេភ្លាម ។ គេឈ្លោះ គេប្រកែកគេដេញ ។ គេឡូឡាស្រែកគំហកទៅអោយអ្នកឃោសនាថា "អញវាយចោលម្រាយឥឡូវ ..." វាណាមួយនៅឈរត្រង់ណា អញចោលបែកក្បាលឥឡូវ ... ។ គេវាយប៉ោតគេទះក្តិតគេស្រែកជេរ គេគប់ គេចោល គេឡើងបណ្តាច់បដា គេដេញវាយ ... ។ របៀបប្រឆាំងតាមកម្លាំងឪទិនមួយស្រែះពីរស្រែះបានធ្វើយ៉ាងស្រួលគ្មានភ្នាក់ងាររក្សាររបៀបរៀបរយហាមប្រាមឡើយ ។ ហើយធម្មតាគេឃើញអ្នកជារត់ចាញ់អ្នកស្រវឹង គេឃើញអ្នកឪទិន និងអ្នកប៉ោត បណ្តេញបង្អាក់អ្នកមេក្រូ ឱ្យឈប់និយាយ ឱ្យសាររោងរត់ទៅទីលំនៅវិញ ។ អ្នកមេក្រូដកថយត្រវីក្បាល ។ ខ្លះជិះឡានរត់ភ្នែកនៅកញ្ចឹងក ។ ខ្លះទៀតអស់សំណើចពោលពាក្យថា "ស្រាខ្លាំងជាងមនុស្ស មែនចេះឱ្យមនុស្ស ជាលែងទៅឆ្កួត លែងដឹងការខុសត្រូវ ..." ។ ចំណែកអ្នកភូមិធម្មតាគ្មានបក្សពួកច្រើនតែរអ៊ូរោលអាលថា : បើវាមិនស្តាប់ទេ ចុះហេតុអ្វីក៏វាទៅសម្តែងថោកទាបឆ្កួតដូចនេះ ... វាមិនខ្មាសគណៈអន្តរជាតិទេ ឬបើឃើញយើងស្រវឹងឆ្កួតដូចនេះ ក្នុងពេលប្រឡងប្រណាំងកសាងជាតិ ...។

# ៦. ស្រីៗ

ក្រោយដែលបងហាមបានចេញបាត់ទៅ គ្រូៗឈប់មកលេងផ្ទះគាត់ទៀត ។ លោកគ្រូម៉េងដែលជាអ្នកធ្លាប់ប្រមូលជើងឈប់ចេញមុខ ។ លោកគ្រូច័ន្ទឈប់អើតតែម្តងការប្រជុំជិះកង់ ហក់ចុះហក់ឡើងទាំងវ៉ូងៗ ទាំងវ៉ូងៗ ពីផ្លូវបំបែកទៅដើមពោធិ៍ទៅគរទៅភូមិឯកើត ក៏បានឈប់ធ្វើ ។ ម្នាក់ៗសុទ្ធតែប្រយ័ត្នមាត់ ប្រយ័ត្នក និយាយអ្វីៗសុទ្ធតែគិត សុទ្ធតែចោលភ្នែកមើលឆ្វេងមើលស្តាំ ។

ដំណឹងចាប់ចងចេះតែមានឮស្ទើររាល់តែថ្ងៃ ។ បន្តិចគេឃើញអាស៊ើបគិញកំពុងបរទៅសាលាស្រុក បរទៅពាម ឆ្លងទៅជើងទិសភូមិ គរ ... ។ បន្តិចគេឮថា គ្រូនេះត្រូវផ្លាស់ចោលទៅក្រចេះ បន្តិចគេឮថាលោកគ្រូនោះទេ មកធ្វើចាងហ្វាងសាលារៀនស្រុកម៉ាស៊ីនស្រូវនេះ ។ ពាក្យចចាមអារាមទាំងនេះបានធ្វើឱ្យក្រុមបងហាមអស់កម្លាំងជាច្រើន ។ សេចក្តីសង្ឃឹមថាមុខជាបានគ្នាគេខ្លះបានរសាយ ។ ម្នាក់បែរជាព្រួយ បារម្ភអនាគតខ្លួនដល់ចូលកងធំវិញ ។ ដើម្បីពង្រឹងស្មារតីក្រុមគាត់ លោកគ្រូច័ន្ទបានហុចយោបល់ថា :

" គង់តែផ្លាស់បញ្ជូនទៅដល់ណាក៏ខ្ញុំមិនរវល់គិត" ។ ឱ្យតែកន្លែងមានមនុស្ស ។ ទៅស្រុកភូមិយើងរួបរួមជាមួយប្រជាជនខំកសាងសាលារៀនទៀត ហើយបបួលគ្រូៗមានចំណេះគ្រប់គ្រាន់ល្មមឱ្យប្រជុំគ្នាបកប្រែ សរសេរក្បួនខ្នាតជាភាសាយើងឱ្យសិស្សរៀន ។ ខ្ញុំមិនខ្វល់ទេតាមតែគេផ្លាស់ចុះ ... ។

ប្រុសៗមិនបានមកផ្ទះបងហាមពិតមែនតែអ្នកសនប្រពន្ធគាត់នៅតែមានភ្ញៀវពេញផ្ទះ ។ ពូព្រឿងចេញចូលផ្ទះគាត់ញឹកដូចដើម ។ អ្នកមួននៅតែមកជាក់ម៉ាស៊ីនដេរអាវរាល់ល្ងាច ។

ម៉ែអាវ៉ាប្រពន្ធលោកគ្រូវ៉ាត នៅត្បូងថ្នល់បំបែកបានឆ្លៀតមកសួរសុខទុក្ខគាត់ដែរ ។ អ្នកប្រពន្ធលោកគ្រូម៉េងបានមកខ្សឹបប្រាប់គាត់ថា : "ប្តីខ្ញុំទៅភ្នំពេញពីថ្ងៃអាទិត្យ

មុនបានជួបពូៗ សុខសប្បាយជាទេ ផ្ដាំថាកុំឱ្យមីងព្រួយគិតពីគាត់ពេក ខំតែរកស៊ីបាន ហើយ" ។

អ្នកប្រពន្ធគ្រូច័ន្ទ បានប្រើអាកូនប្រុសច្បងគាត់យកសម្លមកឱ្យអ្នកសនញ៉ាំ ។

ឯចំណែកម៉ែអាថាប្រពន្ធលោកគ្រូច័ន្ទមកញ៉ាំជាងគេ ។ គាត់រួសរាយណាស់ ហើយចេះនាំអ្នកសននិយាយកែអផ្សុកពីនេះពីនោះ ។ អាកប្បកិរិយាស្មោះត្រង់ស្និទ្ធស្នាលបានធ្វើឱ្យហ៊ាននិយាយប្រាប់ពីទុក្ខគាត់ ។ ព្រឹកមួយអ្នកប្រពន្ធលោកគ្រូថាន់ត្រឡប់មកពីផ្សារ ចូលទៅលេងអ្នកសន ។ នៅតែពីរនាក់ស្ងាត់ដូចនេះ អ្នកសនបានសួរថា :

- នាងបានដឹងដំណឹងពីពូនាងទេ ហើយម៉េចទៅប្អូនម៉ៅ

- ឪពុកអាថាបានទៅកំពង់ ពីថ្ងៃព្រហស្បតិ៍ មុនកាលដាច់ខែ ។ គាត់បានទៅជួបគ្រូម៉ៅនៅគុកយកបារីទៅឱ្យ ... ។ ម៉ែអាវ៉ាក៏គេបានយកក្រូចទៅឱ្យដែរ ។ ម៉ែអាវ៉ានិយាយប្រាប់ខ្ញុំថា គាត់ព្រួយចង់យំអាណិតគ្រូម៉ៅ តែគ្រូម៉ៅនៅតែស្រស់ញញឹមគ្មានក្រៀមបន្តិចឡើយ ។

- អរតែបានសុខសប្បាយទៅ ខ្ញុំអុជធូបថ្វាយព្រះរាល់ល្ងាចឱ្យតែគាត់បានចេញឆាប់ ។ ចុះចំណែកពូនាងៗបានដឹងដែរឬទេ ។

- គាត់សុខសប្បាយជាទេ កុំទៅព្រួយពីពូខ្លាំងពេកមីងអើយ ស្រុកយើងសុខសប្បាយហើយ ពូមិនស្លាប់ទេ... ។ លាក់បាំងអ្វីកាលពីឆ្នាំទៅមួយនោះ កាលស្រុកយើងនៅច្បាំងនោះ ពេលដែលឪអាថាត្រូវទៅកំពង់ ពេលនោះខ្ញុំព្រួយចិត្តណាស់ ... ។ ពេលឪអាថាទៅបាត់ម្ដងៗ ខ្ញុំដេកមិនលក់ទេខ្លាចតែគាត់ត្រូវបញ្ជូនទៅឆ្ងាយត្រូវគ្រាប់ស្លាប់... ។ តែឥឡូវគង់តែគាត់ទៅបាត់មួយខែ ក៏មិនសូវព្រួយដែរ ... ។ បើដល់ចូលកងវិញ គេផ្លាស់គាត់ទៅចុងកាត់មាត់ញក មេមត់ចំការលើក៏ខ្ញុំមិនព្រួយដូចមុនដែរ... ។ ស្រុកយើងសន្តិភាព ហើយមិនព្រួយពីត្រូវគ្រាប់ឆេះផ្ទះទៀតទេ ... ។

- នាងខុសខ្ញុំ ។ លោកគ្រូមានប្រាក់ខែ ។ នាងគ្មានគិតពីធ្វើស្រែ ហើយខែនេះភ្លៀងស្រួលផង ។ ខ្ញុំនៅស្រែបីទៀតមិនទាន់ដាស់ ... ។ មីខ្សុនក្មួយខ្ញុំវាឈប់ទៅម៉ាស៊ីន

ស្រូវរំវល់តែមើលគោ ហើយខ្ញុំទៀតក៏ខានទៅលក់ឯចំការ...។ ម្យ៉ាងទៀតស្រុកសាន្តត្រានហើយគួរតែបានសុខមូលត្រកូលគ្នាបែរទៅជាព្រាត់ប្រាសរកស៊ីលែងបានទៅវិញ ។

- កុំព្រួយអីរកជួលគេធ្វើសិនទៅ ឪអាថាបានប្រមូលគ្នាជាមួយលោកគ្រូម៉េង លោកគ្រូច័ន្ទ និងគ្រូឯទៀត ថាវៃប្រាក់គ្នា គាត់យកមកជូនមីងជួលគេភ្ជួរ ។ តាមខ្ញុំដឹងប្រហែលពីរបីថ្ងៃទៀត គេយកមកជូនមីងហើយ ... ។

- ខ្ញុំអរគុណនឹងគំនិតនេះណាស់ ។ តែសព្វថ្ងៃនេះអ្នកស្រែរវល់គ្រប់គ្នា ។ គេកំពុងបង្ខំធ្វើស្រែគេដែរ គ្មាននរណាមួយទាន់ទំនេរទេ ។ គង់តែមានលុយក៏មិនងាយជួលបានភ្លាមដែរ ... ។

ពូព្រឿងបានដេកលបស្ដាប់នៅល្វែងផ្ទះគាត់ ឮដូចនោះក៏បានឆ្លើយកាត់ថា :

មិនដឹងជាទុក្ខសោកដល់ណាទៀតទេ ។ កុំព្រួយពីរឿងធ្វើស្រែនោះឱ្យតែមានបាយឱ្យអ្នករាស់ស៊ី ។ ចាំខ្ញុំនិយាយពឹងអ្នកខ្វារនៅភូមិមុខឱ្យរកគ្នាជួយភ្ជួរ ... ។

ប្រពន្ធលោកគ្រូថាន់ត្រេកអរបានកាត់ភ្លាមថា :

ពូខំរកអ្នកភ្ជួរឱ្យបានចុះ ចំណែកបាយទឹកស្រេចលើយើង ... ។ ខ្ញុំយកដំណឹងនេះប្រាប់ឪអាថា គាត់មុខជាត្រេកអរមិនខាន ... ។

ថាដល់ត្រង់នេះ គាត់ក្រោកហើយនិយាយត :

ដល់ពេលដាំបាយ ។ ខ្ញុំសូមលាពូ មីងសិនហើយ ភ្ជួររាស់ថ្ងៃណាប្រាប់ខ្ញុំឱ្យដឹងមុន ... ។

# ៧. លោកប្អូនរបស់ពូព្រឿង

ពូខ្វាវនៅភូមិមុខផ្ទះពូព្រឿងជាអ្នកចង់ចេះចង់ដឹង ។ គាត់បានប្រមូលសៀវភៅកាសែតចាស់ៗ ពីផ្ទះបងហាមរាល់អាទិត្យគាត់យកចិត្តទុកដាក់រៀនសូត្រ ហើយចាំរឿងច្រើន ។ ពេលគាត់ជួបលោកគ្រូច័ន្ទ ជួបម៉ៅម្តងៗ គាត់បានចោទបញ្ហាជាក់ស្តែងឱ្យជួយរករបៀបកែប្រែការរស់នៅ អ្នកស្រែចំការ ។ ការឆ្លាតវៃយប្រសប់ដោះស្រាយផ្សំនឹងអាកប្បកិរិយា និងមិនចេះច្រឡោតក្អេងក្អាងរបស់គាត់បានធ្វើឱ្យលោកគ្រូច័ន្ទ យកចិត្តទុកដាក់សរសើរគាត់ច្រើន ។ លោកគ្រូច័ន្ទបានឧស្សាហ៍តំណាលប្រាប់គេឯងពីគាត់ថា: “ ពូខ្វាវជាអ្នកប្រាជ្ញស្រុកស្រែ” ។ គាត់អាចធ្វើសមាជិកមួយយ៉ាងចំណានក្នុងសមាគមអ្នកស្រុកស្រែយើងទៅថ្ងៃក្រោយ ... ។

តាំងពីបងហាមទៅបាត់ ពូខ្វាវនៅតែទៅមកផ្ទះបងហាមដូចធម្មតា ។ គាត់មកសួរសុខទុក្ខអ្នកសន សួរដំណឹងបងហាមមករកខ្ចីសៀវភៅ ... ។

យប់មួយគាត់មករកខ្ចីកាសែត ខ្ចីសៀវភៅ ។ ពូព្រឿងបានឃាត់គាត់អង្គុយលេង ។ ពូព្រឿងបានសួរគាត់ពីធ្វើស្រែរួចហើយឬនៅ ពីសង្ឃឹមបានស្រូវស៊ីគ្រប់ ឬទេឆ្នាំនេះ ពីយោបល់អ្នកភូមិគាត់ ... ។ បន្ទាប់មកពូព្រឿងបានបន្ទោសគាត់ថា :

អញធុញតែអ្នកខ្វាវមកកាលណាសួរតែដដែលៗ ។

- សួរអីដដែលនោះ ...

- សួររកតែក្រហម ...

- មិនសួរឯណាបានមនុស្សល្អដូចអ្នកហាម ម៉េចឥឡូវលោកបងបានដំណឹងពីគាត់ទេ ?

- កុំព្រួយពីក្រហមពេក ។ ប្រហែលវានោះមិនងាយងាប់ទេ

- តាំងពីគាត់ទៅខ្ញុំខ្សត់កាសែតមើល ... ។ តែឥឡូវខ្ញុំរកទំនុកឃើញហើយ ។ អ្នកភូមិខ្ញុំគេសុខចិត្តចូលប្រាក់គ្នាតាមធនធានខ្លះ ៥៖០០ ខ្លះ ២៖០០ រាល់ខែប្រមូលគ្នា

ជាវកាសែត ... ។ ខ្ញុំជួបលោកគ្រូច័ន្ទពីថ្ងៃមុន ខ្ញុំបានសូមឱ្យគាត់ចុះឈ្មោះជាវឱ្យខ្ញុំស្រេច ... ។

- ល្អចេះរកទំនុកឃើញ តែអញនៅតែមិនពេញចិត្តអ្នកខ្វាវឯងទៀត ។ អ្នកខ្វាវឯងចូលចិត្តតែនិងក្រហមដែលទៅបាត់ ហើយដែលជួយផងមិនកើត ។ តាមអញៗយល់ថា ត្រូវជួយមនុស្សនៅផ្ទះល្អជាង ... ។

- ជួយនរណា ?

- នៅតែបើកភ្នែកមើលមិនឃើញទៀត ។ ចំពោះរឿងចង់ជួយដាក់គ្រោងការណ៍នេះ អញមានរឿងមួយយកមកឱ្យអ្នកខ្វាវឯងជួយពិចារណា ?

- រឿងដូចម្ដេចទៅ ?

- កាលអញទៅឱ្យពេទ្យមើលភ្នែកនៅភ្នំពេញ អញទៅសំណាក់ផ្ទះប្អូនអញនៅម៉ុំផ្សារសួនពេទ្យចិន

- ប្អូនលោកបងណាមួយ ? លោកសុភានោះឬ ?

- ហ្នឹងហើយ

- ខ្ញុំបានស្ដាប់លោកដែរ លោកជាអ្នកប្រសប់និយាយណាស់ ពូកែពន្យល់ពីសេរីភាពយ៉ាងស្រស់ ហើយចេះដោះស្រាយនឹងពាក្យចាក់ដោតរបស់គេណាស់ ... ។

- ខាងវោហារនោះពិបាករកមនុស្សប្រដូចហើយ ។ គេចេះនិយាយណាស់... ។ គេជិតមួយខែ អញត្រូវគេពន្យល់ពីសេរីភាព ពីសិទ្ធិ ហើយប្រពន្ធគេទៀត ក៏នៅមិនស្ងៀមដែរ បានពួតដៃគ្នាជាមួយប្ដីទាមទារសេរីភាព សិទ្ធិសមភាពប្រុសស្រីបោះឆ្នោតផ្ញើតំណាងរាស្ត្រ ... ។

- ស្រីៗឥឡូវដើបហើយ លោកបងឃើញទេ នាម៉ឺនរាស្ត្រគ្រប់គ្នាស្រឡាញ់សេរីភាព ... ។

- ដឹងជាគេស្រឡាញ់សេរីភាព សិទ្ធិស្មោះត្រង់ ឬមិនស្មោះត្រង់ទេ នៅមួយខែជាមួយអញដូចជាឃើញ គេឈ្លីជាន់សេរីភាពសិទ្ធិទៅវិញ ... ។

- ម៉េចតែលោកបងនិយាយដូចនេះ ?

- នៅផ្ទះគេ អញឮរាល់តែថ្ងៃពាក្យចំអេសចំអាសជេរបញ្ចោរខ្ញុំកំដរ គេប្រើពាក្យអាក្រក់ណាស់ ... ។ល ។ អញសង្កេតទៅឃើញថានៅផ្ទះគេ អ្នកតូចតាចគ្មានសេរីភាពសិទ្ធិបន្តិចសោះឡើយ ។ គេជួលទិញមនុស្សខ្ចប្រើមួយថ្ងៃៗវាល់ៗល្ងាចគ្មានឈប់សម្រាកសោះ ។ គេបង្ខាត់អ្នកតូចទាំងនោះឱ្យលុតក្រាប ឱ្យដើរទា ឱ្យចេះលុតជង្គង់ពេលគ្នា និយាយរកខ្លួន ឱ្យចេះបត់ជើងគាល់នៅវេលាបាយ... ។ ខាងស៊ីចុក ខាងដំណេកនោះស្រេចតែម្តងហើយ គេឱ្យគ្នាស៊ីសំណល់បាតចាន គេឱ្យគ្នាដេកកៀនជើងក្រាន ... ។

ឃើញដូចនេះអញទ្រាំមិនបាន ។ ថ្ងៃមួយសុភា គេយកកាសែតមកពន្យល់ថាលទ្ធិប្រជាធិបតេយ្យល្អដូចនេះ ល្អដូចនោះ ។ អញស្តាប់ហើយសួរតបវិញថា : " ប្អូនចង់ឱ្យរាស្ត្រមានសេរីភាពសិទ្ធិនោះល្អហើយៗចំជាត្រូវ ។ តែមុននឹងទៅផ្សាយជួយស្រោចស្រង់អ្នកដទៃ មុននឹងបន្ទោសថា អ្នកនេះប្រឆាំងប្រជាធិបតេយ្យត្រូវស្រោចស្រង់អ្នកនៅក្នុងផ្ទះខ្លះផង ។ គួរណាស់តែលៃលកដូចម្តេចឱ្យជើងឈ្នួលរបស់ខ្លួនមានសេរីភាពសិទ្ធិ មានបាយស៊ីគ្រប់គ្រាន់ផង ... គួរណាស់កុំទុកគ្នាជាមនុស្សដូចជាន់ដើមហើយកុំយកគ្នាមកបំបត់បំបែនអោយវារជើងពីរជើងបួននិយាយនឹងឯងនោះ "

- លោកឆ្លើយវិញថាម៉េច ?

- គេបន្ទោសថាអញមិនទាន់យល់ប្រជាធិបតេយ្យនៅឡើយ ។ គេថាមានលុយត្រូវតែជួលមនុស្សប្រើតាមបំណងគេ ។ គេថា គេនឿយហត់រៀនសាលាច្បាប់ សាលាលិស្សេ គេត្រូវតែមានអំណាចប្រើខ្ញុំកំដរអញ្ចឹង ... ។

- លោកបងឯងឆ្លើយដូចម្តេចវិញ ?

- អញប្រាប់គេថា បើគេស្រឡាញ់សេរីភាព គេត្រូវស្រឡាញ់សម្រាប់មនុស្សទូទៅ គេមិនមែនស្រឡាញ់សម្រាប់តែគ្រួសារ តែពូជខ្លួនទេ ... ។ សុភាពគេថាកុំឱ្យអញយល់ផ្ដាសដូចនេះ ? អ្នកក្រតូចតាចនេះ គឺមកពីកម្មផលជាតិមុនទេតើ កែមិនឡើងឡើយ ... ។ អញឆ្លើយវិញថា កម្មមិនកម្ម អញមិនដឹងទេ តែអ្នកស្រែចំការតូចតាចស្រេកឃ្លានសេរីភាពពិតៗ មិនចូលចិត្តធ្វើខ្ញុំកំដរគេទេ ... ។ សុភាគេបន្ទោសថាពិបាកនិយាយណាស់ជាមួយអ្នកស្រែមិនដឹងអ្វីស្ដាប់គ្នាមិនបានទេ ... ។ ឱ្យតែឃើញគេអាណិតរាប់អានបន្តិចចុះតាំងធ្វើគ្រាន់ប្ញើហើយ ប៉ុន្តែដេរមាត់ដូចជាន់មុនទេ ... ។

- អើខ្ញុំនឹកឃើញហើយ ពូខ្វាវបានលាន់មាត់

- នឹកឃើញអ្វី ?

- បងសែមភូមិឯជើងក្បែរវត្តបានពន្យល់ប្រាប់ខ្ញុំថា ក្នុងលោកសព្វថ្ងៃមានប្រជាធិបតេយ្យពីរប្រជាធិបតេយ្យបារាំង អាមេរិចកាំង ជាប្រជាធិបតេយ្យចាស់ ដែលឱ្យសេរីភាព សិទ្ធិទៅតែនាម៉ឺន អ្នកមាន ហើយប្រជាធិបតេយ្យថ្មីមួយទៀត ឱ្យសេរីភាពទៅប្រជាជនតូចតាចពិតប្រាកដ ។ បងសែមបានប្រាប់ខ្ញុំថា នៅស្រុកប្រជាធិប-តេយ្យថ្មី អ្នកស្រែចំការកម្មករបានមានសេរីភាព ហើយធូរគ្មានគេមាក់ងាយ ទេ ... ។

ពូព្រឿងបានកាត់ភ្លាមថា :

អញមិនគិតពីប្រជាធិបតេយ្យថ្មីចាស់ទេ ការដែលអញខំលើករឿងនេះមកនិយាយ អញចង់ឱ្យឯងឃើញថា មាននមនុស្សច្រើនណាស់គិតតែការឆ្ងាយការក្រៅការធំសម្រេចផងមិនបាន ឯការតូច ការធ្វើភ្លាមបានក្នុងផ្ទះមិនព្រមគិតសោះ ដូចអ្នកខ្វាវឯងនេះជាដើម ។ ឱ្យតែជួបអញថ្ងៃណា គិតតែអានិតក្រហម គិតតែសួររកក្រហម ឯប្រពន្ធក្រហមនៅមុខគ្មាននរណាជួយដាស់ស្រែ អ្នកខ្វាវឯងមិនបានគិតគូរនឹងគេឯងជួយភ្ជួរគ្នាម្ដងឡើយ ... ។

- ខ្ញុំយល់ហើយ ចំពោះរឿងស្រែកុំព្រួយ ។ ចាំខ្ញុំទៅបបួលគេជួយ ។ ភ្ជួរថ្ងៃណាប្រាប់មក ... ។ ពូព្រឿងឃើញពូខ្វាវទទួលដូចនេះស្រែកហៅអ្នកសនថា :

- នាងសនៗ នែឥឡូវអ្នកខ្វាវសុខចិត្តភ្នំរឱ្យហើយ ។ ប្រាប់មក ។

មួយស្របក់ក្រោយសំឡេងអ្នកសនបានលេចឮ : ថ្ងៃស្អែកខ្ញុំប្រាប់ ចាំខ្ញុំទៅសួរអ្នកស្នងសិន ។ និយាយស្រុះស្រួលគ្នារួច ដូចនេះពូព្រឿង និងពូខ្វាវបានឈប់និយាយ ។ ពូព្រឿងផឹកទឹក ពូខ្វាវមូរបារីស្លឹកសង្កែអុជជក់ផ្សែងទ្រលោម ។ បន្ទាប់មកគាត់និយាយថា " យប់ជ្រៅហើយមិនទាន់ដុតភ្នក់គោផង ខ្ញុំសូមលាលោកបងសិនហើយ " ។

# ៨. គុកខ្មែរ

ថ្ងៃចេះតែដើរ ... ។ សីហា ដាច់ ថ្ងៃពីរកញ្ញាបានមកដល់ ។ ម៉ៅបានត្រូវដោះលែងចេញពីគុក ។ ដំណឹងនេះបានធ្វើឱ្យម៉ែអាថាអរហួសរកចាប់អីវ៉ាន់មិនចំពោះបន្តិចចាប់ត្រី បន្តិចចាប់បន្លែ ។ ភូមិម៉ាស៊ីនស្រូវ អ្នកភូមិផ្ទល់បំបែកបានជួយត្រេកអរគ្រប់គ្នា ។ សេចក្តីសង្ឃឹមបានមកដល់ក្រុមគេវិញខ្លះ ។

ជាដំបូងម៉ៅបានចូលទៅលេងអ្នកភូមិខាងត្បូងផ្លូវបំបែកជិតម៉ាស៊ីនស្រូវធំ ទៅផ្ទះលោកគ្រូជាន់ ទៅផ្ទះលោកគ្រូច័ន្ទ រួចគាត់បានត្រឡប់ទៅជាមួយលោកគ្រូវ៉ាតសួរសុខទុក្ខពូព្រឿងនិងអ្នក សន ។

ចេញពីគុកសើមៗ ម៉ៅមានសម្បុរជ្រះជាងធម្មតា ហើយមានចរិតនឹងដូចដើម ។ ឃើញដូចនេះ ពូព្រឿងបានថា :

- នៅតែមិនព្រមគ្រៀមសោះ ។ ម៉េចអស់ប៉ុន្មានថ្ងៃដែរ លោកគ្រូក្នុងគុកនោះជ្រះផងឥឡូវ

- ជិតមួយខែដែរ ។

- រស់នៅដូចម្តេចក្នុងគុកពិបាកយ៉ាងណា ?

ម៉ៅមិនបានឆ្លើយ ពូព្រឿងភ្លាមទេ ។ គាត់ហួតកន្ទុយបារីចងចំកំលៀងខៀវពីហោប៉ៅអាវសីមិគាត់ ។ បន្ទាប់មកគាត់ស៊កបារីទៅក្នុងកន្ទុយបារីនោះ រួចសូមភ្លើង

ពូព្រឿងអុជ ។ លោកគ្រូវ៉ាតឃើញលាន់មាត់ថា :

- បងបានកន្ទុយបារីល្អផង ថ្លៃប៉ុន្មាន ?

- មានតែមួយទេនៅស្រុកយើងនេះ "ម៉េចឆ្លើយសើចចេញធ្មេញសស្គុស" ពូឈុំបានឱ្យខ្ញុំនៅគុក

- អើម៉េចទៅឈុំ "ពូព្រឿងបានសួរ" ។ ស្នងជើងវាដែលត្រូវគេវាយនោះជាហើយ ឬនៅ ?

ជាហើយ ប៉ុន្តែគាត់ដើរមិនត្រង់ដូចដើមទេ ។ គាត់ដើរវៀចៗ ។ មិនដឹងថាថ្ងៃណាទេបានគាត់រួច ។ សាលាដំបូងមិនព្រមកោះហៅសួរទៀតសោះ... ។ គណៈអន្តរជាតិបានយកចិត្តទុកដាក់ដែររឿងនេះ តែដូចជាមិនបានផល សព្វថ្ងៃគាត់ត្រូវគេចាត់ឱ្យបោសច្រាសក្នុងគុហា ... ។

- ចុះអាអេងដែលគេចាប់មុនលោកគ្រូនោះវាយ៉ាងណាដែរ ?

- គាត់នៅជាមួយពូឈុំដែរ ។ គេចោទគាត់ថាលាក់កាំភ្លើង ឥឡូវគេលែងកោះហៅទៅសួរទៀតហើយ ប្រហែលជាគេឃុំចោលនៅគុករហូតហើយមើលទៅ ។

លោកគ្រូវ៉ាតបានកាត់ :

- ម៉ែអេងមកជួបខ្ញុំពីព្រឹកមិញ ពកូនតូចមួយមកផង ។ គាត់ប្រាប់ខ្ញុំថាកំពុងគិតគូរ...។ គាត់បានបញ្ចាំស្រែមួយថ្លៃពីរពាន់រៀល យកទៅជូនលោកកាន់សំណុំរឿងនៅសាលាដំបូង ... ។ គាត់ថាគេសន្យាឱ្យអេងរួចខ្លួនអាទិត្យក្រោយនេះដែរ ... ។

- ចុះបងហាមអ្នកមានដំណឹងពីគាត់ទេ " ម៉ៅបានងាកទៅសួរអ្នកសន" ។

- ចាសសុខសប្បាយទេ ចាំតែពេលឈប់តឹងតែងបន្តិចបានមកវិញ ។ ចុះលោកគ្រូរស់នៅដូចម្ដេចទៅ គេមានធ្វើបាបទេ ខ្ញុំចង់ទៅសួរណាស់ តែរវល់ពេករកដើរទៅណាផងមិនបាន ។

- មើលយ៉ាងម៉េចទៅគុកប្រាប់ខ្ញុំផងក្រែងលោះដល់វេនខ្ញុំ "លោកគ្រូវ៉ាតបានសួរ" យប់គេចាប់បងទៅ ខ្ញុំលោកគ្រូម៉េងបានទៅតាមភ្លាមតែសួរដំណឹងបងទៅមិនលេចសោះ ។

- ក្រោយដែលគេចាប់ខ្ញុំទៅភ្លាម គេជិះកខ្ញុំដាក់ឡាន នាំទៅឃុំនៅប៉ុស្តិ៍ប៉ូលិសកំពង់អស់មួយយប់ ។ គេគ្មានធ្វើបាបខ្ញុំទេ អ្នកដែលយាមខ្ញុំយប់នោះស្រួលណាស់ ។ គាត់បានឱ្យខ្ញុំដេកក្នុងប៊ុយរ៉ូធ្វើការ មិនបានបញ្ចូលខ្ញុំទៅក្នុងសែលលូលទេ ... ។ គាត់ដើរចុះឡើង បន្តិចៗគាត់មកអើតមើលខ្ញុំ គាត់ប្រាប់ខ្ញុំថា បើត្រូវការបារី ទឹកកក កាផេប្រាប់គាត់ ។ ហើយគាត់ថាគាត់មានក្មួយមួយមានចិត្តគំនិតដូចខ្ញុំដែរ ។ ព្រឹកឡើងគិញម្នាក់បាននាំខ្ញុំទៅប្រគល់លោកព្រះរាជអាជ្ញា ដែលបន្ទាប់មកបានឱ្យអ្នកយាមម្នាក់បណ្ដើរខ្ញុំទៅបន្ទប់ស៊ើបសួរសុភាចារបុរស ... ។

- គេចោទបងរឿងអ្វី ?

- ដូចប្អូនវ៉ាតឯងបានធ្វើសាក្សីឃើញស្រាប់ហើយ ។ មនុស្សប្អូនដប់នាក់បានផ្ដិតមេដៃប្ដឹងថាខ្ញុំទិតៀនដល់រដ្ឋាភិបាល ហើយថាខ្ញុំនិយាយមិនពិត ... ។ ខ្ញុំបានឆ្លើយបដិសេធពាក្យចោទទាំងស្រុង ហើយបានសូមឱ្យលោកសុភាជួយបកស្រាយមាត្រា១០៣នៃរដ្ឋធម្មនុញ្ញដែលបានបដិសេធច្បាប់ណារំលោភលើសេរីភាព សិទ្ធិ ដែលបានចងក្នុងមាត្រា៩ នៃរដ្ឋធម្មនុញ្ញយើង ... ។ លោកសុភាបានឆ្លើយថាលោកជាចៅក្រម លោកមិនមែនជាអ្នកជំនាញបកស្រាយច្បាប់រដ្ឋធម្មនុញ្ញទេ ហើយលោកបានប្រាប់ខ្ញុំថា ខ្ញុំជាកូនក្ដី ត្រូវតែចាំឆ្លើយបានហើយ ... ។

- បងបានឆ្លើយដូចម្ដេចទៀតទៅ ?

- ឃើញលោកបន្ទោសដូចនេះ ខ្ញុំក៏សួរលោកថែមទៀតថា តើខ្ញុំត្រូវឃុំទេហើយនរណាស៊ីញ៉េឃុំខ្ញុំ ហើយតើអាងមាត្រាក្រមព្រហ្មទណ្ឌរដ្ឋបវេណីណាមួយ ។ លោកនៅស្ងៀមដាក់មុខមើលឆ្វេងស្ដាំ ហើយប្រាប់ខ្ញុំថា " លោកត្រូវរកសាក្សីថែម

ទៀតមក ខ្ញុំនឹងកោះមកសួរបញ្ជាក់"។ មួយស្របក់ក្រោយរួចពីសញ្ជឹង ចោលភ្នែកមើលខ្ញុំ លោកនិយាយតិចៗថា " ខ្ញុំមានកូនច្រើនគ្មាននរណាចិញ្ចឹមវាទេ បើខ្ញុំខានធ្វើការ ។ បើលោករួចខ្លួនឆាប់ ខ្ញុំជាមនុស្សមួយរូបដែលរីករាយត្រេកអរជាងគេ ... ។

ថាចប់ទទួលថ្ងៃត្រង់ដល់ម៉ោងឈប់ធ្វើការ លោកក៏ចុចកណ្ដឹងហៅអ្នកយាមឱ្យនាំខ្ញុំទៅឃុំក្នុងគុក រហូតដល់ថ្ងៃពីរ កញ្ញា ... ។

- ប៉ុណ្ណឹងហៅលោកល្អហើយ " ពូព្រឿងលាន់មាត់" ចុះដល់គុកយ៉ាងណាដែរពួកអ្នកយាមអ្នកគុកដូចម្ដេចទៅ ?

ម៉ៅបានសិកបារីមួយទៀតក្នុងកន្ទុយបារីអុជបឺតផ្សែងហុយទ្រលោមនិយាយ :

កន្លងទ្វារគុកភ្លាម មានអ្នកយាមមាឌធំមុខអុតបានទទួល ។ គាត់និយាយធំៗសម្លុតថា : មានលុយកាក់ទេផ្ញើទុកមក មានរឿងអ្វីហ្នឹង អើនយោបាយទៀតហើយ តែថាប់យ៉ាងហ្នឹងមានកន្លែងណាដាក់ ចង្អៀតណែនប៉ែស ហើយសែលលូលនេះ ... ។

គាត់បាននាំខ្ញុំបញ្ចូលក្នុងសែលលូលដែលមានមនុស្សប្រាំមួយនាក់នៅចាំ។ រួចកាលណាគាត់បានចាក់សោក្រាំងៗពីក្រៅ ។

ដើម្បីឱ្យដឹងការរស់នៅក្នុងគុកយ៉ាងដូចម្ដេច ខ្ញុំសូមជូនកំណាព្យមួយ ។ កាណាព្យនេះមិត្តសូផនដែលទើបមករួមសង្គមជាតិយើងក្រោយ កិច្ចព្រមព្រៀងហ្សឺណែវបានលបតែង ។

បន្ទាប់មកម៉ៅបានហួតក្រដាសមួយសន្លឹកហុចទៅឱ្យលោកគ្រូវ៉ាតនិយាយថាណេះប្អូនវ៉ាតមើលទៅធ្វើបទឱ្យអ្នក និងពូស្ដាប់ផង ។

លោកគ្រូវ៉ាតបានយកមកអានធ្វើបទថា :

# ៩. បរិយាកាសគុក

ច្រាវៗ ខ្នោះដែកទង្គិច ឮ    ម៉ោងជាងប្រាំភ្លឺអ្នកគុកក្រោក
ឡើងពីដំណេកមាត់កាកកោក    នាំគ្នាឡើងក្រោកដោះខ្នោះជើង ។
ពីគ្រប់ល្វែងធំឆ្អេះស្អុយឆ្អួល    ឬពីសែលលូលទិសត្បូងជើង
អ្នកគុកដើរចេញមុខសើងម៉ើង    រៀបកាយរៀបជើងប្រុងប្រាណចាំ ។
លើដីទីវាលអង្គុយទាប    ជាជួរក្បាលត្រៀបមួយជួរប្រាំ
រួចអ្នកតម្រួតត្រូវវេនចាំ    រាប់ក្បាលជួរប្រាំផ្ទៀងបញ្ជី ។
ស្រេចហើយកាលណាតម្រួតប្រាប់    ឡូឡាចំណាប់បន្ទោសស្តី
វាយដំច្រំធាក់គ្មានប្រណី    ប្រើសុទ្ធសម្តី អា និង មី ។
ចាត់ខ្លះទៅឡានកើបសំរាម    ខ្លះទៀតរបាមមានចាស់ថ្មី
ត្រូវគេដាក់ខ្នោះបណ្តើរខ្ចី    ទៅសួរសេចក្តីតុលាការ ។
ខ្លះទៅថែសួនផ្ទះលោកធំ    ខ្លះចាត់ទៅបំបោសលាសា
ខ្លះបោសចង្ហួរគុកគុហា    សម្អាតទីធ្លាឱ្យបាត់ធុំ ។
ខ្លះនៅជើងក្រានដណ្តាំបាយ    ពួកនយោបាយត្រូវនៅជុំ
គេហាមមិនឱ្យចេញពីក្រុម    ខ្លាចតែអប់រំក្រុមចោរបាន ។
ឱ្យចេះស្តាប់មិត្តស្គាល់សត្រូវ    ឱ្យរកផ្លូវត្រូវកែខ្លួនបាន
ឱ្យយល់ជំនួយវែងវំខាន    បើចង់ខ្មែរបានទុក្ខគ្មានល្ហែ ។
ចក្រពត្តិអាមេរិចមេចោរប្លន់    ជ្រៀតជ្រែកមកប្លន់ទឹកដីខ្មែរ
ប្រើគ្រប់កលល្បិចបំបែកខ្មែរ    ដោយបានផ្លាស់ប្រែភេទជំនួយ ។
ជំនួយសេដ្ឋកិច្ចមកយោធា    បង្ខំប្រជាឱ្យក្រំព្រួយ
ឱ្យញាក់ឱ្យផ្អើលដូចគេស្ទួយ    ក្រោកឡើងងើបជួយដេញចក្រពត្តិ ។
នាំយករឿងនេះចូលគ្រប់ទី    ជជែកវក់វីពេញគុកវត្ត
ឃើញជាក់អាមេរិចមេចក្រពត្តិ    ចង់ព័ទ្ធស្រុកខ្មែរឱ្យខ្ញុំវា ។

*គុកកំពង់ ថ្ងៃ ២៥ - ៨ - ៥៥*

# ១០. យប់ក្នុងគុក

ប្រាវៗកំឡុងប្រាំនាទី អ្នកគុកក្បាលមីរចូលខ្នោះជើង
រួចអ្នកតម្រួតដើរចុះឡើង រាប់ក្បាលពួកយើងចុះបញ្ជី ។
ឈ្ងោកមើលក្រោមគ្រែកៀនជញ្ជាំង ក្រែងមានបំបាំងលាក់ឡោស៊ី
ដែកគោលខ្សែលួសកាសែតថ្មី ក្រែងលាក់ក្រោមដីបង្កប់នៅ ។
ក្រោយមកតម្រួតទាញកូនសោ បិតទ្វារចាក់សោពីខាងក្រៅ
ទុកឱ្យអ្នកគុកដេកហាលនៅ ក្នុងក្រោលលំនៅធុំឆ្អេះស្អុយ ។
ក្នុងក្រោលអ្នកគុកចាប់ជដែក មានរឿងប្លែកៗកំសាន្តព្រួយ
ខ្លះនឹកឃើញឈ្មោះមិត្រមកជួយ ឱ្យបារីមួយលបឱ្យការ ។
ខ្លះខឹងតម្រួតជេរវាយស្តី ខ្លះបន្ទោសស្តីតុលាការ
ត្រូវសំណូកគេភ្លេចមុខការ ដើរផ្លូវមុសាអាងដាក់គុក ។
ខ្លះគិតបារម្ភអនាគត ព្រោះជិតកំណត់ចេញពីគុក
ត្រឡប់វិលវិញទៅភូមិស្រុក ទៅជួបអស់មុខបងប្អូនមិត្រ ។
ខ្លះផ្តើមនិយាយនយោបាយ អត្ថាធិប្បាយរឿងអាមេរិច
ចូលមកក្នុងស្រុកនាំវីវក អាវុធសន្ធឹករាយពេញដី ។
ឱ្យមានចាប់ចងពេញទាំងស្រុក ទន្រ្ទានបុករុកជ្រៀតគ្រប់ទី
ចាក់ចុចឱ្យខ្មែរបែកសាមគ្គី ដើម្បីវាស្រួលជិះជាន់យើង ។
ស្នូរសព្ទជដែក ឮស្នូរអ៊ូ បំបាត់អស់ស្នូរនៃខ្នោះជើង
ដល់ម៉ោងប្រាំពីរស្ងូត្រធម៌ឡើង ស្នូរជើងប៉ុន្មានបាត់ស្ងួនស្ងៀមឈឹង ។
លុះស្ងូត្រធម៌ចប់ហើយកាលណា សញ្ញាភ្លើងភ្លែតប្រាប់នៅហ្នឹង
ឱ្យឈប់ ឮមាត់ស្ងប់ឱ្យឈឹង អ្នកគុកសញ្ជឹងឃើញឧបទ្រព ។
ពាក្យខ្សឹបពាក្យខ្សុចនៅមានឮ អ្នកខ្នោះបន្លឺពាក្យចុបៗ

អ្នកវេនចាំយាមខំស្ទុះហុច ធុងអាចម៍ស្អុយឡប់ឱ្យនោមជុះ ។
យប់កាន់តែជ្រៅសូរចម្លែក គ្រោកក្រាកខ្នោះដែកលាន់ចម្រុះ
លាយសូរចុបៗហៅនោមជុះ សូរសព្ទទាំងនោះយប់គុកខ្មែរ ។

គុកកំពង់ ថ្ងៃ ២៧ - ៨ - ៥៥

មើលចប់លោកគ្រូវ៉ាតបត់ទុកដាក់ហោប៉ៅអាវគាត់និយាយថា ៖ ខ្ញុំទុកយកទៅឱ្យប្អូនបងស្តាប់ ... ។ យីនៅគុកនៅតែមានដាក់ខ្នោះទៀត ។ ចម្លែក កាលពីឆ្នាំ១៩៤៧ ពេលសម្តេចរដ្ឋធម្មនុញ្ញ ខ្ញុំឃើញគេមិនដាក់ច្រវាក់អ្នកគុកធ្វើការទេនៅកំពង់ ... ។

យីនៅគុកមានសូត្រធម៌ផង ... ពូព្រឿងបានភ្ញាក់ ហើយស្អីមានធ្វើចុបៗ ហៅជុះនោម ... គ្រោកក្រាកខ្នោះ ដែកវេទនាណាស់ ... ។

- លោកគ្រូសំរាន្តយប់ដូចម្តេចទៅ ? អ្នកសនបញ្ជាក់ គេមិនដាក់ខ្នោះទេឬ ?

- យើងនៅគុកបន្ទប់តូចគ្នាប្រាំមួយនាក់ដេកចំហៀងខ្លួន ។ តម្រួតចាក់សោពីក្រៅ ។ ពេលដែលអ្នកគុកក្នុងក្រោលត្រូវបង្ខំសូត្រធម៌ យើងក្នុងសែលលួល បានបបួល ជជែករឿងផ្សេងៗ ហើយមានថ្ងៃណាមួយព្រួយអផ្សុកតប់ប្រមល់ពេកក៏បានបបួលគ្នាច្រៀងចម្រៀងផ្សេងៗ ។ មិត្រសូផនសំឡេងពីរោះបទពីរោះច្រើនណាស់ ។ គាត់បានច្រៀងបទ “ផ្ការំដួលខៀវខ្ចី” បទបង្កើនផល “ជ្រូកមាន់ទា” ។ ពីរោះអស្ចារ្យហើយ ចាំតែគាត់រួចពីគុកមកខ្ញុំនាំគាត់មកច្រៀងប្រណាំងនឹងថាសសារីមប៉ាក់ ស្មៀនឈិន ... ។

ម៉ៅនិយាយជក់ញាប់មាត់ ។ លោកគ្រូវ៉ាតឃើញពេលកាន់តែល្ងាចបានកេះគាត់ថា “ល្មមហើយបង តស់យើងទៅផ្ទះយើងវិញ ក្រែងមានភ្ញៀវមកចាំ” ។

លោកគ្រូវ៉ាតបានក្រោក ម៉ៅក្រោកតាម រួចអ្នកទាំងពីរលាពូព្រឿង អ្នកសនមកផ្ទះបៀតម៉ាស៊ីនស្រូវវិញ ... ។

# ១១. ពេលចូលភេទ

... ១៦ កញ្ញា ថ្ងៃចូលរៀន ។ លាហើយវិស្សមកាលពីរខែ ។ លាហើយវ៉ាកង ធំ ។ អ្នកភូមិស្រីប្រុសបានប្រជ្រៀតគ្នាទៅមុខសាលារៀនរកកន្លែងឱ្យកូនរៀន ។ ម្នាក់ៗ សុទ្ធដឹកដៃអាច្រម៉ក់របស់ខ្លួនមក ។ ខ្លះមុខរីកសើចដាក់គ្នា ។ ពួកនេះបានកន្លែងឱ្យកូន រៀន ។ ខ្លះទៀតមុខក្រៀមដឹកដៃកូនត្រឡប់ទៅផ្ទះវិញ ពោលត្អូញប្រាប់គេឯងថា " ឯងខំចូលលុយសង់សាលានឹងគេដែរនៅតែខ្វះទៀត" ។ ពេញអស់ហើយគ្មានកន្លែង ណាឱ្យអាច្រម៉ក់រៀនទេ ។ ដឹងឆ្នាំណាទេបានគេឱ្យគ្រូ បានគេសង់សាលារៀនថែម ទៀត ។ ដឹងឆ្នាំណាទេ ក្មេងៗបានកន្លែងរៀនគ្រប់គ្នា ។

បើប្រជាជនខ្វល់ប្រជ្រៀតរកកន្លែងឱ្យកូន ឯក្រុមគ្រូក៏មានកង្វល់ដែរ ។ នៅថ្ងៃ ចូលរៀន សំបុត្របង្គាប់មួយខ្ទាស់បីច្បាប់បានផ្ញើមកដល់ មន្ទីរចាត់ការសាលា ។ សំបុត្រ ទីមួយបានបង្គាប់លោកគ្រូវ៉ាតឱ្យផ្លាស់ទៅត្រើយម្ខាង ។ សំបុត្រទីពីរបានហូត លោក គ្រូថាន់ទៅដាក់នៅចំការ ។ សំបុត្រទីបីបានបង្គាប់លោកគ្រូច័ន្ទឱ្យបោះពួយឆ្លងខេត្តពីរបី ទៅដែនលាវ ។

ការផ្លាស់ប្តូរនេះមិនបានបញ្ជាក់ គ្រូនៅម៉ាស៊ីនស្រូវផងទេ តែព្រឹត្តិការណ៍នេះ បានឱ្យគ្រូទៅនិងគ្រូនៅមានយោបល់ផ្សេងៗ ។

លោកគ្រូវ៉ាតបានបញ្ចេញអារម្មណ៍ថា :

"..... ខ្ញុំមិនចូលចិត្តនឹងការផ្លាស់ទេ បើសិនជាខ្ញុំបង្រៀនសិស្សមិនជាប់ ។ ឆ្នាំទៅ គ្រាន់ដែរ ជាប់បានជាង១០នាក់ ចូលវិទ្យាល័យកំពង់ ។ ម្យ៉ាងទៀតខ្ញុំស្តាយណាស់មិន បាននៅស្រុកនេះបានយូរបន្តិចទៀត ។ ស្រុកម៉ាស៊ីនស្រូវបានចងចិត្តខ្ញុំជាខ្លាំង ។ ខ្ញុំ សប្បាយនឹងបានរួបរួមជាមួយមិត្ត ជាគ្រូ និងប្រជាជនបង្កើតសមាគម ពង្រីកសាលា ។ ពិតមែនតែខ្ញុំក្រដាក់តុងទីនមួយក្បាល ខ្ចីគេកាលម៉ែអាវ៉ាឆ្លងទន្លេ នៅតែខំលៃលក ២០ - ៣០៖០០ រាល់ខែជួយសមាគមសង់សាលា ។ ខ្ញុំស្តាយណាស់ដោយមិនបានជួយ ពង្រីកសាលា និងអនុវិទ្យាល័យនៅស្រុកនេះក្នុងឆ្នាំក្រោយៗ ។ "

លោកគ្រូថាន់បានថ្លែងថា :

"…. ស្រុកម៉ាស៊ីនស្រូវជាស្រុកកូនខ្ញុំ ជាភូមិម៉ែក្មេកឪក្មេកខ្ញុំ ។ យើងបានទាំងសន្សំសង់ផ្ទះមួយនៅទីនេះផង ។ ការផ្លាស់ចេញពីស្រុកនេះ ធ្វើឱ្យខ្ញុំរំខានច្រើន ។ ម៉ែអាថាមិនដាច់ចិត្តទៅចោលផ្ទះសម្បែងគេទេមើលទៅ ។ ហើយម្យ៉ាងទៀតសព្វថ្ងៃខ្ញុំជាប់ទទួលក្មួយបីនាក់ឱ្យនៅរៀនផង ។ នឹកដល់ក្មេងទីទ័លទាំងនោះ ស្ទើរប្រេះដើមទ្រូង ។ ខ្ញុំមិនអស់ចិត្តសោះ បើកាលណាខ្ញុំបង្រៀនមិនកើត ខ្ញុំខ្វះសមត្ថភាព ខ្ញុំខ្ជិល ។ ប៉ុន្តែតាំងពីធ្វើការមក ខ្ញុំបានឡើងថ្នាក់រាល់ពីរឆ្នាំ … ។ មិនគួរឡើយយករឿងក្រៅពីការបង្ហាត់បង្រៀនមកជាទីអាងផ្លាស់ដូចនេះទេ …" ។

លោកគ្រូ ច័ន្ទបានស្តីថា :

"… មិនមែនទើបមួយខែ មួយឆ្នាំទេ ដែលខ្ញុំមកនៅស្រុកម៉ាស៊ីនស្រូវនេះ ។ ខ្ញុំមកតាំងពីស្រុកនេះមានសាលាតែមួយនៅមុខសាលាស្រុក តាំងពីស្រុកនេះមិនទាន់មានម៉ាស៊ីនស្រូវម្ល៉េះ ។ ខ្ញុំបានមកនៅស្រុកនេះ ១៣ឆ្នាំហើយ តាំងពីខ្លួនមួយរហូតដល់មានប្រពន្ធ កូន៥នាក់ឥឡូវ ។ កាលប៉ុន្មានឆ្នាំមុន គេហៅខ្ញុំទៅកំពង់ ខ្ញុំបានសុខចិត្តទៅតែកន្លះឆ្នាំ រួចឆ្នាំត្រឡប់មកស្រុកវិញ ។ ខ្ញុំជាប់ចិត្តនឹងស្រុកនេះជាពន់ពេក ។ ខ្ញុំទុកស្រុកនេះជាស្រុកកំណើតខ្ញុំទៅហើយ ។ លាក់បាំងអ្វីការឃ្លាតចេញពីស្រុកនេះ ធ្វើឱ្យខ្ញុំស្រណោះ មិនខុសពីខ្ញុំឃ្លាតចេញភូមិខ្ញុំមករៀនវត្តបួទុមកាលពីកុមារទេ ។ ខ្ញុំសោកស្តាយខ្ញុំរលឹកមិត្តភ័ក្តិដែលលេងបាយខុំ ប៉ាក់គ្រលុំ បេះផ្លែអំពិល កាលពីក្មេង យ៉ាងណាក៏ខ្ញុំស្រណោះមិត្រភ័ក្តិ បងហម ពូសែម ពូសម ពូខ្មាវ … ដូចនោះដែរ ។ តែខ្ញុំសង្ឃឹមថាខ្ញុំទៅនេះមិនយូរអង្វែងឡើយ ។ ពេលសម្រាក ពេលវ៉ាកង ខ្ញុំមុខជាឆ្លៀតមកលេងវិញជាមិនខាន ហើយយើងមុខជាបានជជែកពិភាក្សាគ្នាពីការកសាងអនុវិទ្យាល័យនៅស្រុកយើង ពីសៀវភៅសិក្សាជាភាសាខ្មែរ ពីការកែប្រែការសិក្សាឱ្យស្របតាមប្រទេសយើងឯករាជ្យ ពីសមាគមគ្រូ ពីការរស់នៅប្រជាជនស្រុកលើ ដែលខ្ញុំទៅនៅជាមួយក្នុង

ពេលខាងមុខនេះ ... ។ ខ្ញុំសង្ឃឹមថាមិត្រយើងមុខជានឹងជួយលើកទឹកចិត្ត គ្រូបន្លាស់ពួកយើងឱ្យមានចិត្តស្មារតី ដូចយើងជាមិនខាន ... ។"

លោកគ្រូម៉េងដែលជាអ្នកនៅបានឱ្យយោបល់ថា :

ការផ្លាស់ប្តូរនេះមិនបានពញ្ញាក់ពួកយើងទេ ។ តែភេទការណ៍នេះបានអោយខ្ញុំព្រួយផងអរផង ។ ព្រួយដោយយើងបែកគ្នា ដោយមិត្រយើងដែលត្រូវចាកចេញទៅឆ្ងាយ ត្រូវបង់ខាតគ្រប់ផ្លូវខាងសម្ភារៈត្រូវចោលទីលំនៅ ត្រូវខ្ចីបុលប្រាក់គេឯងធ្វើដំណើរទៅ ... ។ អរដោយជឿជាក់ថា មិត្រយើងដែលត្រូវទៅ សុទ្ធជាអ្នកសំខាន់ៗអាចពាំយកទៅផ្សាយ និងបណ្តុះនៅទីកន្លែងថ្មីនូវឧត្តមគតិរបស់យើង ... ។

# ១២. ហួសជួស

មួយអាទិត្យក្រោយថ្ងៃទទួលសំបុត្របង្គាប់ លោកគ្រូច័ន្ទ លោកគ្រូថាន់ លោកគ្រូវ៉ាត បានចេញពីស្រុកម៉ាស៊ីនស្រូវ ទៅទីកន្លែងថ្មីតែសព្វខ្លួន ។ បន្លាស់គាត់បានមកជំនួសវិញ ។ ដូចគ្រូទៅ គ្រូមកសុទ្ធតែត្រូវផ្លាស់មកមិនស្រួលដែរ ។ លោកគ្រូថ្មីទាំងបីសុទ្ធតែមានសកម្មភាពខ្លាំងគ្រាន់ កាលពីវ៉ាកងធំ ។ ជីវភាពដូចគ្នា គំនិតដូចគ្នា ។ បើគ្រូនៅពាម នៅកំពង់ ... ត្រូវគេហាមឃាត់យ៉ាងណា គ្រូស្រុកម៉ាស៊ីនស្រូវក៏បានទទួលការហាមឃាត់យ៉ាងនោះដែរ ។ គេសុទ្ធតែគ្រូស្រទាប់ក្រោម រស់នៅកៀនកោះស្រែចំការក្នុងវត្ត ក្នុងភូមិជាមួយប្រជាជនដូចគ្នា ។ គេត្រូវចោទប្រកាន់ ហើយបានទទួលគ្រោះទណ្ឌកម្មដូចគ្នា ។ ដូចនេះហើយ ការសាមគ្គីរវាងគ្រូៗ នៅស្រុកម៉ាស៊ីនស្រូវគ្មានបានល្អក់បន្តិចឡើយ ។ ផ្ទុយទៅវិញ គ្រូថ្មីបាននាំនូវការពិសោធរបស់ខ្លួន ហើយបានក្រេបជញ្ជក់ការពិសោធពីស្រុកម៉ាស៊ីនស្រូវ បន្ថែមទៅវិញ ... ។

រាល់ថ្ងៃកន្លងទៅ ភេទការណ៍ជាច្រើនបានប្រែប្រួលនៅស្រុកម៉ាស៊ីនស្រូវ ។ លោកចាស់ស្រុកបានផ្លាស់ទៅនៅខែត្រផ្សេង ។ លោកថ្មីបានមកដល់ ។ បរិយាកាសតឹងតែងបានធូរស្រាល ។ អ្នកដែលត្រូវចាប់ពី កក្កដា សីហា កញ្ញា បានត្រូវដោះលែងខ្លួន ។ នាយអេងបានរួចខ្លួនត្រឡប់មកជួបម៉ែឪវិញ ។ ឯចំណែកពាក្យចចាមអារាម រកចាប់ចងក៏បានបាត់ស្ងាត់ ។ ប៉ូលិសមុយបានមកលបខ្សឹបប្រាប់អ្នកសនថា ៖

ស្រុងយើងស្រួលវិញហើយ អាហមគ្មានរឿងអ្វីទេ ហៅវាមកធ្វើស្រែវិញចុះ... ។

ពូសែមភូមិឯជើងបានឈប់គេច ។ គាត់ចេញមកប្រកបរកស៊ីដូចដើមវិញ ។ លោកគ្រូថាន់ លោកគ្រូវ៉ាតបានឆ្លៀតមកលេងស្រុកម៉ាស៊ីនស្រូវ នៅពេលឈប់សម្រាកមួយឬពីរថ្ងៃ ... ។ លោកគ្រូច័ន្ទបានផ្ញើដំណឹងមកថា គាត់បានសុខសប្បាយជាទេ ហើយបានសូមឱ្យមិត្តភ័ក្តិខំបន្តការកសាងសមាគមតទៅទៀត ... ។

នៅក្រោយអ៊ុំទូកខែកត្តិក បងហមបានត្រឡប់មកភូមិគាត់វិញ ។ គ្រូចាស់ ក៏ដូចគ្រូថ្មី អ្នកភូមិគរ ក៏ដូចអ្នកភូមិដើមពោធិ៍ បានត្រេកអរទៅសួរសុខទុក្ខគ្រប់គ្នា ។ ប៉ូលិសមុយមិនបានធ្វើ គ ថ្លង់នឹងមិត្រចាស់របស់គាត់ឡើយ ។ ល្ងាចមួយចេញពីធ្វើការ គាត់បានទៅលេងមិត្រគាត់ ។ គាត់មានទាំងយួរស្រាមួយដប និងពងមាន់បីដំបទៅផង ។ គាត់ហៅពូព្រឿងឱ្យមករួមវង់ជាមួយគាត់ និងសម្លាញ់គាត់នៅលើគ្រែគៀនជញ្ជាំងខាងជើង ។ គាត់និយាយដោយរីករាយថា :

កុំតែចេះគេចទាន់ កុំអីខ្ទោះស្រេច ។ អញអរលែងនិយាយហើយ ពេលដែលមកជាមួយចីដោយ រកអាឯងមិនឃើញ ... បើសិនជាឃើញហោចណាស់ ក៏បីខែដែរអានាង ... ។

- អញមានទោសអ្វី ?

- ចាំបាច់មានទោស ឃើញទេលោកគ្រូម៉ៅ ថៅហ្វាយនាយអាវែងនោះជាប់ជិតមួយខែទទេ ហើយនឹងគាត់ផង ។ តើគាត់មានរឿងអី ? អញបានជួបគាត់នៅគរម្ដងដែរ ។ អញបានស្ដាប់គាត់និយាយ អញគ្មានឃើញគាត់និយាយប៉ះពាល់អ្វីឡើយ ។ គាត់និយាយពីការរស់នៅវេទនារបស់រាស្ត្រពីយើងត្រូវរកសេរីភាព សិទ្ធិពីរបៀបដោះស្រាយ កែប្រែការរស់នៅពីជំនួយអាមេរិចកាំង បំបាត់អព្យាក្រឹត អធិបតេយ្យភាពខ្មែរយើង ។ គាត់គ្មានចាក់ដោតនរណាមួយឡើយ ។ ម្ល៉ឹងហើយនៅតែមានអាជា អាអ៊ុត ... មុខក្រាស់ផ្ដិតមេដៃចាប់គាត់យកទៅដាក់គុកមួយខែនៅកំពង់ ... ។

- បើដឹងអញ្ចឹងដែរម៉េចតែអាវែងដើរចាប់គេ

- នៅតែឆ្ងល់ទៀត អញបានប្រាប់អាវែងញឹកហើយ បើឯងធ្វើកុំចេញមុខពេក ។ អញមិនមែនអ្នកនយោបាយទេ ។

- អាមុយឯងនេះជាប្រដាប់ម៉ាស៊ីនសម្រាប់តែគេមួលឱ្យសម្រេចនយោបាយគេ ។ នៅជាមួយបារាំង អាវែងបារាំង ជាមួយជប៉ុន អាវែងជប៉ុន ។ ជាមួយអាមេរិចកាំង

អាវ៉ែងអាមេរិចកាំង ។ មិនល្អទេរបៀបនេះ ។ យើងកើតមកជាមនុស្សត្រូវតាំងខ្លួនជាមនុស្ស ។ អ្វីដែលហៅមនុស្សនោះ មនុស្ស គឺត្រូវស្គាល់ខុស ស្គាល់យុត្តិធម៌ ស្គាល់អយុត្តិធម៌ ...

- កុំធ្វើគ្រាន់ អាហាម ប៉ូលិសមុយនិយាយយកដៃទះក្បាល បងហាម ។ អាវ៉ែងពីដើមនៅតែជាមួយនឹងអញ កាលនៅចាំប៉ុស្តិ៍ផឹកស្រាមិនឱ្យលុយចិនដូចតែគ្នា ... ។

- អញពុលតាមបារាំងវាបង្ខិក ឥឡូវអញឃើញទោសអញ ស្តាយអញខំកែប្រែ ។

- ឈប់និយាយអាហាមពីរឿងនយោបាយទៀត ... ។ អញមកនេះអញមកសប្បាយ ។ អញមកបបួលអាវ៉ែងផឹកទេតើ

ថារួចប៉ូលិសមុយលើកកែវដាក់សួរគ្រេប ហើយគោះពងហុត ។ គាត់ហៅអ្នកសនថា :

អ្នកៗ សូមអំបិលបន្តិចមក មានកន្ទួត អម្ពិលទេយកមក

អ្នក សន ញញឹមបានយកកន្ទួត អម្ពិលពីរបីក្តួរមកឱ្យ ។ ប៉ូលិសមុយដាក់មួយកែវ ហើយថែមមួយកែវទៀត ។ បន្តិចគាត់ទាររកនេះ បន្តិចគាត់ទាររកនោះ ។ គាត់អង្គុយ បន្តិចគាត់ក្រោកនិយាយផ្កាដៃជើងតែម្នាក់ឯង ។ គាត់និយាយគ្រប់ ។ បន្តិចគាត់និយាយពីចៅហ្វាយនាយគាត់មុនៗ បើកក្បាលបៀនៅក្នុងផ្ទះ ពីលោកខ្លះមានស្រីច្រើននៅរាយគ្រប់ឃុំ ពីលោកខ្លះទៀតប្រើគាត់ឱ្យកំហែងទិញកូនក្រមុំគេ ៥០០៖០០ ។ គាត់និយាយពីលោកថ្មីស្រួលមិនដែលជេរម្រ៉ាយប៉ូលិសដូចលោកមុនទេ... ។ អ្នក សន ដួសបាយជូនក៏គាត់មិនពិសា ។ គាត់ពឹតតែពីផឹកមួយកែវ ហើយមួយកែវទៀត ។ អស់ស្រាពីដបគាត់ទាររកទៀត ។ បងហាមឃាត់គាត់មិនស្តាប់ ។ គាត់ថាគាត់មិនទាន់ស្រវឹងទេ ថាពោះគាត់ចាស់ផឹកមិនទាន់ដល់ដួសទេ ។ មុខគាត់ឡើងក្រហមភ្នែកគាត់ក៏ក្រហមបែកញើសពេញទាំងខ្លួន ។ គាត់ក្រោកឡើងទ្រេតទ្រោតត្លួញឈឺក្បាលចង់ក្អួត ។ គាត់ដួលដេកនៅលើគ្រែស្តោះទឹកមាត់ញឹក ។ ខ្លួនគាត់ធំស្រាហ្មង ។ គាត់ដួលដេកបាត់មាត់ ។

បងហាមបានយកក្រមាគ្របដណ្ដប់ឱ្យនិយាយថា : "អាមុយហួសដូសហើយ" ខ្ញុំពីដើមដៃគូនឹងវា តែឥឡូវខ្ញុំដុសក្អែលអាណានិគមនិយមបានខ្លះ... ។

បន្ទាប់មកគាត់អង្គុយជជែក ជាមួយពូព្រឿងនៅលើគ្រែជញ្ជាំងខាងត្បូងវិញ ឯអ្នកសន ក៏បានលើកចានទៅលាងនៅផ្ទះបាយ ... ។

## ១៣. វ៉ាកងខែចេត្រ

ខែចេត្រសាលារៀនបិទទ្វារសម្រាកខែក្ដៅ ។ សិស្សវិទ្យាល័យ អនុវិទ្យាល័យខ្លះបានត្រឡប់ទៅស្រុកកំណើតវិញ ខ្លះមានឆ្លៀតទៅលេងបងប្អូនមាមីងនៅខេត្តផ្សេងៗ ។ ខ្លះទៀតបានទៅជាមួយឪពុកម្ដាយមិត្តភ័ក្តិមើលប្រាសាទបូរាណឬទៅកំសាន្តនៅកែបមាត់សមុទ្រ ... ។ គ្រូបង្រៀនខ្លះនៅស្រុកស្រែចំការបានចូលមកលេងក្រុង ។ គ្រូខ្លះដែលត្រូវផ្លាស់ពីខែ កញ្ញាមុនបានវិលមកលេងកន្លែងចាស់ខ្លួនវិញ ។

នៅខែសម្រាកចូលឆ្នាំនេះ មុខគ្រូចាស់ៗខ្លះ ដែលបានទៅបាត់ពីដើមឆ្នាំ បានលេចមកស្រុកម៉ាស៊ីនស្រូវវិញ ។ លោកគ្រូថាន់ បាននាំប្រពន្ធកូនគាត់មកមុនគេ ។ លោកគ្រូវ៉ាតពិតមែនតែសំណាក់កំពង់ជាមួយឪពុកក្មេកគាត់ក៏មិនភ្លេចមកអើតកន្លែងចាស់គាត់ឡើយ ។ លោកគ្រូច័ន្ទបានត្រឡប់មកជួបជុំប្រពន្ធកូនគាត់ក្រោយគេបន្តិច ។

នៅវ៉ាកងតូចនេះ គ្រូតូចតាចស្រុកម៉ាស៊ីនស្រូវបានគួរសមទាក់ទងរកគ្នាយ៉ាងស្និទ្ធស្នាល ។ បន្តិចលោកគ្រូម៉េង ធ្វើការបញ្ជៀវអញ្ជើញលោកគ្រូច័ន្ទ លោកគ្រូថាន់... ទៅលេងផ្ទះ ។ បន្តិចម៉ែអាថាបានផ្ញើម្ទាស់ពីចំការយកទៅជូនប្រពន្ធលោកគ្រូច័ន្ទ ... ។ អ្នកសនប្រពន្ធបងហាមបានទៅដល់ផ្ទះសាកសួរសុខទុក្ខអ្នកទើបមកដល់ថ្មី ... ។ ការនឹករលឹករាប់អានគ្នា បានធ្វើឱ្យគេដើរទៅមករកគ្នាលែងញញើតញញើម មើលឆ្វេងស្ដាំដូចកាលទើបចូលរៀនទៀតហើយ ។ គេគុយទាវ កាផេ នៅផ្លូវបំបែកផ្ទះអាចិកលាងនិយាយចំអែចំអន់គ្នាលេងសើច ក្អាកក្អាយ ។ គេដណ្ដើមគ្នាចេញលុយឱ្យចិនថា :

" អ្នកស្ទឹងត្រែងកុំអី ទុកឱ្យអ្នកស្រុកម៉ាស៊ីនស្រូវចេញបានហើយ " ។

ក្រៅពីការប្រជុំគ្នានៅផ្សារ គេបានឆ្លៀតទៅសួរសុខទុក្ខមិត្តនៅភូមិ ឃុំ ។ គេសួរដំណឹងពីភូមិដើមឫស្សី ។ គេជិះកង់ទៅលេងគរ គេទៅជួបនឹងបងសែមនៅភូមិជើង ។ គេសួរដំណឹងពីនាយអេង គេនឹកអនុស្សាវរីយ៍ពីគ្រូម៉ៅ ។ គេចង់ទៅកំពង់ គេចង់ទៅពាម គេចង់ទៅភូមិពូសន ។ គេចង់ធ្វើគ្រប់ ... តែពេលចូលរៀនជិតមកដល់ ។ លោកគ្រូច័ន្ទក៏លាន់មាត់ថា :

" មិនទាន់បានអីផងដល់ពេលទៅវិញហើយ" ។

លោកគ្រូម៉េងឃើញថ្ងៃបែកគ្នាជិតមកដល់ បានស្នើបងហាមឱ្យរៀបចំផ្ទះលាងមិត្តដែលត្រូវទៅ ។ បងហាមបានពឹងអាចិកគ្រុយដែលជាអ្នកដៃស្រស់ខាងគុយទាវគោនៅក្បែរម៉ាស៊ីនស្រូវមុខផ្ទះគាត់ អាចិកគ្រុយបានកាប់មាន់ កាប់ទាយកមកឱ្យនិយាយប៉ៃឡាំសើចលេងថា " អញឡើងហើយពួកអាបងហាមឯងនេះឡូចតែអញអីចឹង ។ អញក្រអញចូលចិត្តតែអាណាជួយអ្នកក្រឡូចស្រុកចិនឥឡូវ ... ។"

ពេលបាយ ផ្កាច់វ៉ាកងគេជួបជុំគ្នាជាងដប់នាក់ ។ លោកគ្រូវ៉ាត លោកគ្រូវ៉េតបានមកតាំងពីកំពង់ ។ លោកគ្រូ សេន បានមកពីពាម ។ គេចំអែចំអន់គ្នាលេង ។ គេសរសើរពីសម្លគេថាបើតែឆ្ងាញ់យ៉ាងនេះមកទៀតហើយ ។ គេថាលោកគ្រូវ៉ាតពូកែលាងចាន ... ។

រួចបាយគេក៏បានចាប់និយាយពីការដែលគេបានជួបប្រទះនៅក្រោយពេលបែកគ្នាប៉ុន្មានខែមុន ។

លោកគ្រូថាន់បានដំអូញមុនគេថា :

- ពិបាកណាស់ស្រុកចំការនោះ ។ ខ្ញុំទ្រាំមិនបានទេ ។ ឆ្នាំក្រោយសូមរត់ហើយ ។ ថាម៉េចក៏ថាចុះពិបាកណាស់ ។ តាំងពីផ្លាស់ទៅខ្ញុំចាយលុយអស់សន្ធឹក ។ គុងទីនមួយក្បាលអស់រលីងមិនដឹងបានអី ... ។ ម៉ែអាថាមិនស្រួល អាកូនតូចឈឺជាប់ ... ។

- ចំណែកខ្ញុំក៏យ៉ាប់ណាស់ដែរ ។ ប្រាក់ខែលែងគ្រប់តែម្តង " លោកគ្រូច័ន្ទបានកាត់ " ។ ឯងនៅឯមេឃ ឯដី ឯណា ឯនោះ ឯកូនប្រពន្ធនៅឯនេះ ។ គេទៅផងមិនបាន ផ្ទះពីរខ្ទីគេចាយរាល់ខែ និយាយពីយ៉ាប់លែងនិយាយខ្ញុំមិនដែលចេញស្តីប្រាប់នរណាទេរឿងនេះ ... ។

ស្តាប់ឮ ដូចនេះ លោកគ្រូម៉េងបានកាត់ :

- មិនមែនតែលោកគ្រូឯងទេ ដែលវេទនា ។ គ្រប់គ្រូតូចតាចស្រទាប់ក្រោមវេទនាដូចគ្នា ។ លោកគ្រូហេង អ្នកគ្រូម៉ន បន្ទាស់លោកគ្រូក៏វេទនាណាស់ដែរ ។ អ្នកគ្រូម៉នត្រូវផ្លាស់មកធ្វើទីនេះ ឃ្លាតពីឪពុកម្តាយចាស់ៗ នៅឯភ្នំពេញឯនោះ ។ ឯចំណែកគ្រូៗ ដែលនៅក៏មិនមែនស្រួលដែរ ។ យើងតឹងទ្រូងជាប់ ។ ដូចលោកគ្រូជ្រាបហើយ មិនចាំបាច់រាប់រៀបឱ្យវែងឆ្ងាយទេ ... ។ លោកគ្រូដឹងហើយ ជួបប្រទះហើយ ... ។ ខ្ញុំជៀសធ្វើនាម៉ឺន តុលាការបាល័ដ្ឋ ព្រោះខ្ពិលអែបអប ខ្ពិលសូក ដល់មកធ្វើគ្រូនៅតែឮសំណូក នៅតែជួបរបៀបលុតក្រាប ។ ឱកាសណាទៅយើងនឹងបានផុតការសម្លុតទៀត ... ។ តើធ្វើដូចម្តេចទៅ ?

គិតមួយស្របក់លោកគ្រូ ច័ន្ទ បានឱ្យយោបល់ :

- យើងខំពង្រីកសមាគមសាលារៀន ខំច្រាកលុយ ខំឡើងប្រក់សាលា តើយើងធ្វើដើម្បីផ្គាប់ផ្គុននរណា ? យើងដែលបានស្ម័គ្រចិត្តរួមគ្នាចាយកម្លាំងកាយ កម្លាំងប្រាក់ដូចនេះមិនមែនដើម្បីបុណ្យសក្តិ ដើម្បីតម្រូវចិត្តលោកនោះក៏ទេដែរ គឺយើងធ្វើដើម្បីកូនប្រជាជន ដើម្បីប្រឆាំងនឹងអវិជ្ជា ។ ការយើងធ្វើនេះបានផលជាក់ស្តែងទេ ? មិនបានដូចបំណងយើងទាំងអស់ពិតមែន តែសាលាដែលទ្រេតទ្រោតធ្លុះធ្លាយ យើងបានទ្រទល់តម្រង់ យើងបានប្រក់ជួសជុល យើងបានទាំងបង្កើតថ្នាក់ពីរថែមទៀត បើកឱ្យកុមារា កុមារីតូចៗបានរៀនជាង១០០នាក់ផង ។ ចំពោះការយើងធ្វើនេះ តើប្រជាជន

ទឹងនឹងយើងទេ ? ប្រជាជនស្រឡាញ់យើងជួយយើងពេញទី មានពួសានជាដើមបាន ទាំងខំធ្វើពាក្យទៅសូមគ្រូពីកំពង់ ពីភ្នំពេញរដ្ឋសភាទៀតផង ។ ម្យ៉ាងទៀត កាលពីដើមឆ្នាំចូលរៀនមុននេះ អ្នកស្រុកម៉ាស៊ីនស្រូវជួយការពារយើងពេញទី ។ គេទាំងបានផ្តិតមេដៃធ្វើញត្តិទាមទារកុំឱ្យមិត្តយើងខ្លះផ្លាស់ចេញពីស្រុកយើងនេះផងតែចំណង ប្រជាជនមិនសម្រេច គឺមកពីយើងមិនទាន់មានកម្លាំងគ្រប់គ្រាន់ធ្វើឱ្យស្តាប់យើង ។ ក្នុងភូមិ ក្នុងឃុំ ក្នុងស្រុក ក្នុងខេត្ត ក្នុងប្រទេស ក្នុងលោក កម្លាំងដែលធំជាងគេ គឺកម្លាំងសាមគ្គី ។ យើងគ្រូស្រទាប់ក្រោមតូចតាចដែលវេទនា ត្រូវចេះរកសាមគ្គីចងបាច់គ្នានៅគ្រប់ឃុំ គ្រប់ស្រុក ឡើងផ្តុំគ្នាធ្វើជាសមាគមគ្រូ ដើម្បីឈានទៅធ្វើសហពន្ធសមាគមគ្រូខ្មែរ នៅប្រទេសយើងទាំងមូល ។ យើងត្រូវចេះរួបរួមជាមួយអ្នកស្រុកម៉ែឪសិស្ស រិះរករបៀបបង្រៀនក្មេងឱ្យឆាប់ចេះ ហើយអប់រំវាឱ្យបានជាមនុស្សមួយល្អ ខ្ពើមអំពើអយុត្តិធម៌ ឱ្យចេះស្រឡាញ់ការហត្ថកម្ម ពលកម្ម ។ យើងត្រូវដុះឱ្យអស់កម្អែលអាណានិគមនិយមដែលនៅក្នុងសាលារៀន ។ យើងត្រូវឆ្លៀតប្រជុំគ្នាតែងក្បួនខ្នាតជាភាសាជាតិយើងឱ្យសិស្ស ឱ្យម៉ែឪសិស្ស ។ យើងមិនត្រូវគិតខុសដេកចាំសៀវភៅបារាំងពីប៉ារីស ពីព្រៃនគរ ពីលោកនេះ លោកនោះឬពីជំនួយអាមេរិចកាំងទេ ។ យើងត្រូវយល់ឱ្យជាក់ថាមានតែគ្រូចេះផ្តុំគ្នាទេ ដែលអាចកែប្រែការរៀនសូត្រឱ្យទៅតាមស្រុកឯករាជ្យ ។ ដោយហេតុនេះហើយ បានជាខ្ញុំមិនសូវគិតពីរឿងផ្លាស់ទៅណាសោះ តាមតែគេដាក់ចុះ តែលាក់បាំងអ្វីពិបាកតែដឹកឥវ៉ាន់ចុះឡើង រើម្តងៗ ខាតមិនតិចទេ ។ កុំអីខ្ញុំមិនរវល់ទោម្ទេញទេ គេដាក់ភូមិណាដាក់ចុះ ។ តាំងពីចូលកងមកខ្ញុំបានបង្រៀនក្មេងវិញ ហើយខ្ញុំបានឆ្លៀតប្រែសៀវភៅបានពីរក្បាលដែរ ។ ខ្ញុំគិតថាដល់ចុងឆ្នាំ ១៩៥៦នេះ រកខ្ចីលុយគេបោះផ្សាយហើយ ។

បងហាមបានស្ដាប់លោកគ្រូច័ន្ទគ្មានប្រែប្រួល ។ គាត់ចេះតែងក់ក្បាលថាត្រូវ ហើយៗ ។ គាត់បានកាត់ថា :

ពីរោះមែន ត្រូវមែន ម្លឹងហើយនៅតែខ្ចាតបានទៀត ។ ណេះយកតែមួយកែវ ពិសាលោកចាងហ្វាង ។

លោកគ្រូច័ន្ទបានយកតែលាងបំពង់កមើលជុំវិញឃើញលោកគ្រូថាន់ដេកគង ថ្ងាស ។ រួចគាត់បានតទៀតថា :

មានតែសាមគ្គីផ្គុំគ្នាដូចបានស្ដីរួចមកហើយនេះទេ ដែលអាចឱ្យយើងរួចពីក្ដីទុក្ខ សព្វថ្ងៃ ។ ខ្ញុំគ្មានឃើញអ្វីទៀតទេ មើលលោកគ្រូរ៉េតមានអ្វីថែមទៀតទេ ... ។

ខ្ញុំគិតដូចតែលោកគ្រូអីចឹង " លោកគ្រូរ៉េតឆ្លើយ" តែការអនុវត្តឱ្យបានដូចជា ពិបាកនៅកំពង់តាំងពីខ្ញុំទៅបង្រៀនប៉ុន្មានខែនេះ ឃើញគ្រូខ្លះនៅជាប់របៀបបុរាណ ច្រើន ហើយហ៊ានបង្អាក់ខ្ញុំកុំឱ្យខ្នះខ្នែងពេកម៉ាំៗ យកតែប្រាក់ខែបានហើយ ។

ចំណែកខ្ញុំវិញឃើញគ្រូច្រើនបានចម្រើន " លោកគ្រូច័ន្ទកាត់" កាលខ្ញុំទៅកំពង់ ស្ពឺឆ្នាំទៅ ធ្វើមេប្រយោគប្រឡងវិញ្ញាបនប័ត្រ ខ្ញុំបានជួបគ្រូ ៤-៥ នាក់មកពីក្រចេះ ពី កំពត ពីសៀមរាប ពីព្រៃវែង ពីតាខ្មៅ ។ យើងបានជជែកគ្នាសុទ្ធតែមានយោបល់ដូចគ្នា ទាំងអស់ ។ គ្រូខ្លះបានសន្យាថា ត្រឡប់ទៅកន្លែងខ្លួនវិញ គិតគូរប្រជុំគ្នា ធ្វើសមាគម សរសេរសៀវភៅ ។

- ខាងពាមក៏យើងគិតដែរ " លោកគ្រូសេនបានកាត់" តែអ្នកបានស្រួលខ្លួន មិនសូវរវល់ទេ ។ ហេតុនេះហើយ បានជាខ្ញុំច្រើនរត់មកជាមួយលោកគ្រូម៉េងវិញ ។

លោកគ្រូម៉េងបានឆ្លើយ :

នៅស្រុកម៉ាស៊ីនស្រូវ ឥឡូវមានគ្រូជិត ១០០ នាក់ ។ យើងមានគំនិតដូចគ្នា ក្នុង ការបង្កើតបណ្ណាល័យមួយទិញសៀវភៅឱ្យប្រជាជនវិញ ។ យើងសង្ឃឹមថាមិនជាយូរ ប៉ុន្មានទេ យើងមុខជាផ្គុំគ្នាធ្វើផ្នែកសមាគមគ្រូបាន ... ។

យប់កាន់តែជ្រៅវោហារកាន់តែខ្សោយ ។ ខ្លះដេកគងថ្ងាស ខ្លះស្ងាប ។ ឃើញដូចនេះ លោកគ្រូម៉េងបានបញ្ចប់ថា ៖ ការជួបជុំនេះមិនឥតប្រយោជន៍ទេ យើងបានផ្លាស់ប្តូរគំនិតគ្នា ហើយបានមូលមតិគ្នាស្ទើរទាំងស្រុង ។ យើងត្រូវខំកែប្រែការរៀនសូត្រយើង ... ។

បន្ទាប់មកលោកគ្រូមួយម្តងៗ បានចេញ ខ្លះជិះកង់ ខ្លះដើរទៅផ្ទះតែរៀងខ្លួន ឯចំណែកលោកគ្រូវ៉ាត និងលោកគ្រូរ៉េតមិនបានទៅវិញទេ គាត់នៅសំណាក់យប់នេះជាមួយបងហាម ។

ចប់

បោះពុម្ពផ្សាយឡើងវិញលើកទី ៣
ដោយគ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ
នៃក្រសួងអប់រំ យុវជន និងកីឡា
ព.ស ២៥៥៩ គ.ស ២០១៥